ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កម្មវិធីគោលនយោបាយអាទិភាពទី៥ និងទី៦
# របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា


ចងក្រងដោយ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**



រាជធានីភ្នំពេញ ខែវិច្ឆិកា ឆ្នាំ២០២៣

# កម្មវិធីគោលនយោបាយអាទិភាពសម្រាប់វិស័យកសិកម្ម

- ការលើកស្ទួយផលិតកម្មកសិកម្ម រកទីផ្សារ និងរក្សាលំនឹងថ្លៃកសិផល តាមរយៈកម្មវិធីហិរញ្ញប្បទាន
- ការដាក់ពង្រាយមន្ត្រីកសិកម្មឃុំ-សង្កាត់
- ការអភិវឌ្ឍសហគមន៍កសិកម្មទំនើប

# បុព្វកថា

ពុកម៉ែពូមីងបងប្អូនប្រជាកសិករ និងជនរួមជាតិជាទីស្រឡាញ់!

កសិកម្មគឺជាវិស័យស្នូល ដែលបានចាក់គ្រឹះយ៉ាងជ្រៅនៅក្នុងប្រពៃណី ទំនៀមទម្លាប់ និងវប្បធម៌នៃសង្គមជាតិខ្មែរជាយូរលង់ណាស់មកហើយ។ រហូតមកដល់ពេលនេះ វិស័យកសិកម្មកម្ពុជាបានរំដោះប្រជាជនខ្មែរពីគ្រោះទុរភិក្ស និងធានាសន្តិសុខស្បៀងក្នុងស្ថានភាពលំបាកនៃវិបត្តិកូវីដ-១៩ ព្រមទាំងបានរក្សាអតិរេកស្រូវអស់រយៈពេលជិត៣០ឆ្នាំកន្លងមកនេះ។

ទោះជាយ៉ាងណា វិស័យកសិកម្មនៅតែមានបញ្ហាប្រឈមមួយចំនួន ដែលតម្រូវឱ្យរាជរដ្ឋាភិបាលដាក់ចេញនូវកម្មវិធីគោលនយោបាយអាទិភាព សំដៅដោះស្រាយឱ្យចំបញ្ហា និងទាន់ពេលវេលា ជូនដល់ប្រជាកសិករប្រមាណជាង ២ លានគ្រួសារ ជាពិសេសដើម្បីធានានិរន្តរភាពសន្តិសុខស្បៀងសម្រាប់ប្រជាជាតិទាំងមូល ទោះក្នុងកាលៈទេសៈណាក៏ដោយ។ បញ្ហាប្រឈមដែលប្រជាកសិករកំពុងជួបប្រទះ មានដូចជា កង្វះទីផ្សារនិងហានិភ័យនៃការធ្លាក់ថ្លៃកសិផលក្នុងរដូវប្រមូលផល កង្វះបច្ចេកទេសកសិកម្មនៅតាមមូលដ្ឋាន ដែលនាំឱ្យការដាំដុះមិនទទួលផលជាអតិបរមា កង្វះទុនវិនិយោគនិងទុនបង្វិល ដើម្បីកែច្នៃផលិតផលកសិកម្ម ហានិភ័យនៃបម្រែបម្រួលអាកាសធាតុ និង បញ្ហាថ្លៃដើមផលិតកម្មខ្ពស់ជាដើម។

គោលនយោបាយអាទិភាពទី៥ និងទី៦ ដែលរាជរដ្ឋាភិបាលកម្ពុជាសម្រេចដាក់ចេញ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះមានដូចខាងក្រោម៖

- លើកស្ទួយផលិតកម្មកសិកម្ម រកទីផ្សារ និងរក្សាលំនឹងថ្លៃកសិផល តាមរយៈកម្មវិធីហិរញ្ញប្បទាន ១០០លានដុល្លារអាមេរិក ដែលនឹង

សម្រួលដល់ខ្សែច្រវាក់តម្លៃផលិតកម្មកសិកម្ម និងធានាតុល្យភាពនៃការផ្គត់ផ្គង់និងតម្រូវការ និងដើម្បីគាំទ្រដល់ការផលិតរបស់កសិករ ក៏ដូចជាតម្រូវការស្បៀងអាហាររបស់ប្រជាពលរដ្ឋកម្ពុជា។

- ដាក់ពង្រាយមន្ត្រីកសិកម្មឃុំ-សង្កាត់ ដើម្បីដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងកង្វះបច្ចេកទេសរបស់កសិករ និងសហគមន៍នៅមូលដ្ឋាន ជួយតម្រង់ទិសដល់កសិករក្នុងការដាំដុះផលិតផលនិងជួយសម្របសម្រួលក្នុងការស្វែងរកទីផ្សារជូនកសិករពេលប្រមូលផល។
- អភិវឌ្ឍសហគមន៍កសិកម្មទំនើប ដើម្បីដោះស្រាយបញ្ហាប្រឈមនៅក្នុងផលិតកម្មកសិកម្មប្រកបដោយប្រសិទ្ធភាព និងមានសេដ្ឋកិច្ចមាត្រដ្ឋាន តាមរយៈការប្រមូលផ្តុំការប្រើប្រាស់ដីផលិតកម្មក្នុងទំហំមួយសមស្របដល់ការប្រើប្រាស់មធ្យោបាយទំនើប កាត់បន្ថយថ្លៃដើមផលិតកម្ម បង្កើនផលិតភាព បង្កើនផលចំណេញ និងបែងចែកផលលាភជូនកសិករប្រកបដោយតម្លាភាពនិងសមធម៌។ ក្នុងការរៀបចំសហគមន៍កសិកម្មទំនើបនេះ មន្ត្រីកសិកម្មឃុំ-សង្កាត់ នឹងក្លាយជាតួអង្គយ៉ាងសំខាន់ក្នុងការគាំទ្រដល់ការកសាង និងទ្រទ្រង់ដំណើរការរបស់សហគមន៍។ បន្ថែមពីនេះ ក្រុមប្រឹក្សាគោលនយោបាយសហគមន៍កសិកម្ម និងមូលនិធិសហគមន៍កសិកម្ម ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវបង្កើតឡើងដើម្បីគាំទ្រដល់សហគមន៍កសិកម្មទំនើប ទាំងផ្នែកនយោបាយ និងហិរញ្ញវត្ថុ សំដៅធានានិរន្តរភាពនៃសហគមន៍កសិកម្មទំនើប និងបង្កើនភាពប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងក្រសួង-ស្ថាប័នពាក់ព័ន្ធ នឹងយកកម្មវិធីគោលនយោបាយអាទិភាពនេះ ទៅអនុវត្តប្រកបដោយប្រសិទ្ធភាព។ ខ្ញុំនឹងបន្តតាមដានការអនុវត្តកម្មវិធីគោលនយោបាយទាំងនេះ ដើម្បីដោះស្រាយបញ្ហាប្រឈមនៅក្នុងវិស័យកសិកម្មឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ ជូនដល់ពុកម៉ែពូមីងបងប្អូនប្រជាកសិករ និងជនរួមជាតិ។

ថ្ងៃចន្ទ ៨ កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

# អារម្ភកថា

ផ្អែកលើបទពិសោធនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណទាំង៤ ដំណាក់កាល ព្រមទាំងទស្សនវិស័យ និងគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្ម របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាពេលកន្លងមក រាជរដ្ឋាភិបាលអាណត្តិទី៧ ក្រោមការដឹកនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅតែបន្តផ្តល់អាទិភាពខ្ពស់ដល់វិស័យកសិកម្ម តាមរយៈការដាក់ចេញនូវកម្មវិធីគោលនយោបាយអាទិភាពទី៥ និងទី៦ ដោយផ្តោតលើការលើកស្ទួយផលិតកម្មកសិកម្ម រកទីផ្សារ និងរក្សាលំនឹងថ្លៃកសិផលតាមរយៈកម្មវិធីហិរញ្ញប្បទាន ១០០លានដុល្លារអាមេរិក ការដាក់ពង្រាយមន្ត្រីកសិកម្មឃុំ-សង្កាត់ និងការអភិវឌ្ឍសហគមន៍កសិកម្មទំនើប។

តាមការចង្អុលបង្ហាញ និងការណែនាំជាបន្តបន្ទាប់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ដោយផ្អែកលើការពិនិត្យវាយតម្លៃយ៉ាងម៉ត់ចត់ពីស្ថានភាពកសិកម្មបច្ចុប្បន្ន និងបញ្ហាប្រឈម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចងក្រងឯកសារកម្មវិធីគោលនយោបាយអាទិភាពទី៥ និងទី៦នេះឡើង ដោយចែកជា៣ជំពូក។ ក្នុងនោះ ជំពូកទី១ រំលេចអំពីទស្សនទាន និងយន្តការក្នុងការប្រើប្រាស់ហិរញ្ញប្បទាន ក្នុងគោលបំណងសម្រួលខ្សែច្រវាក់ផលិតកម្ម រក្សាតុល្យភាពតម្រូវការនិងការផ្គត់ផ្គង់ ដើម្បីធានាលំនឹងថ្លៃកសិផលសំខាន់ៗ ឱ្យស្ថិតក្នុងកម្រិតសមរម្យ។ ជំពូកទី២ លើកឡើងអំពីផែនការជាក់ស្តែងក្នុងការជ្រើសរើស ពង្រាយ និងគ្រប់គ្រងមន្ត្រីកសិកម្មឃុំ-សង្កាត់ ដើម្បីធានាប្រសិទ្ធភាពក្នុងការផ្តល់សេវាប្រឹក្សាបច្ចេកទេសកសិកម្ម និងទីផ្សារ ជូនប្រជាកសិករ និងសហគមន៍កសិកម្មនៅមូលដ្ឋាន។ ជំពូកទី៣ ពិពណ៌នាអំពីទស្សនទាន និងផែនការអភិវឌ្ឍន៍សហគមន៍កសិកម្មទំនើបដែល

មានសេដ្ឋកិច្ចមាត្រដ្ឋាន សំដៅលើកកម្ពស់ភាពប្រកួតប្រជែងផលិតកម្មកសិកម្មឱ្យមានប្រសិទ្ធភាពក្នុងកម្រិតកសិ-ឧស្សាហកម្ម។ ជំពូកនេះក៏មានរំលេចអំពីយន្តការក្នុងការប្រើប្រាស់មូលនិធិសហគមន៍កសិកម្មឱ្យមាននិរន្តរភាព និងដំណើរការនៃក្រុមប្រឹក្សាគោលនយោបាយសហគមន៍កសិកម្ម ដើម្បីតម្រង់ទិសការអភិវឌ្ឍសហគមន៍កសិកម្មទំនើបឱ្យទទួលបានជោគជ័យ។

ក្នុងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្នុងនាមប្រជាកសិករ ព្រមទាំងសហគមន៍កសិកម្ម យើងខ្ញុំសូមគោរពថ្លែងអំណរគុណ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានផ្តល់នូវទស្សនវិស័យ មធ្យោបាយ ហិរញ្ញវត្ថុ និងធនធានមនុស្ស សម្រាប់ទ្រទ្រង់និងកែទម្រង់វិស័យកសិកម្មឱ្យកាន់តែមានភាពប្រកួតប្រជែងខ្ពស់ ប្រកបដោយបរិយាបន្ន និងភាតរបរិស្ថាន សំដៅធានានិរន្តរភាពសន្តិសុខស្បៀងជូនប្រជាពលរដ្ឋកម្ពុជាគ្រប់រូប។ យើងខ្ញុំសូមប្តេជ្ញាអនុវត្តកម្មវិធីគោលនយោបាយអាទិភាពទី៥ និងទី៦នេះ ឱ្យទទួលបានជោគជ័យ ដោយសហការជាមួយគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍនានា ដើម្បីលើកកម្ពស់ជីវភាពប្រជាកសិករ និងជំរុញការអភិវឌ្ឍវិស័យកសិកម្មឱ្យកាន់តែល្អប្រសើរឡើងថែមទៀត។

ថ្ងៃចន្ទ ៨ កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣

**រដ្ឋមន្ត្រី**

**ឌិត ទីណា**

# មាតិកា

បុព្វកថា
អារម្ភកថា
ជំពូកទី១៖ កម្មវិធីគោលនយោបាយការលើកស្ទួយផលិតកម្មកសិកម្ម រកទីផ្សារ និងរក្សាលំនឹងថ្លៃកសិផល តាមរយៈកម្មវិធីហិរញ្ញប្បទាន ..... 1
១. សេចក្តីផ្តើម ..... 1
២. វិធានការរក្សាស្ថិរភាពថ្លៃ ..... 2
២.១ វិធានការទូទៅដែលមានឥទ្ធិពលលើថ្លៃកសិផល ..... 2
២.២ វិធានការគ្រប់គ្រងថ្លៃកសិផលផ្ទាល់ ..... 3
៣. ក្រុមការងារចម្រុះសម្របសម្រួល ..... 4
៣.១ សមាសភាព ..... 4
៣.២ តួនាទី ភារកិច្ច និងការទទួលខុសត្រូវ ..... 5
៤. លេខាធិការនៃក្រុមការងារចម្រុះសម្របសម្រួល ..... 6
៥. សេចក្តីសន្និដ្ឋាន ..... 7
ជំពូកទី២៖ កម្មវិធីគោលនយោបាយការដាក់ពង្រាយមន្ត្រីកសិកម្មឃុំ-សង្កាត់ ..... 8
១. សេចក្តីផ្តើម ..... 8
២. គោលបំណង និងលទ្ធផលរំពឹងទុក ..... 9
៣. តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់មន្ត្រីកសិកម្មឃុំ-សង្កាត់ ..... 10
៤. រចនាសម្ព័ន្ធដឹកនាំ និងគ្រប់គ្រង ..... 11
៥. ថវិកា និងការគាំទ្រ ..... 12
៦. គោលការណ៍ និងនីតិវិធីនៃការជ្រើសរើស ..... 12
៧. សេចក្តីសន្និដ្ឋាន ..... 13
ជំពូកទី៣៖ កម្មវិធីគោលនយោបាយការអភិវឌ្ឍសហគមន៍កសិកម្មទំនើប ..... 15
១. សេចក្តីផ្តើម ..... 15

២. បញ្ហាប្រឈមនៃសហគមន៍កសិកម្មបច្ចុប្បន្ន ......16
៣. សហគមន៍កសិកម្មទំនើប ......17
៣.១. គោលបំណង ......18
៣.២. លក្ខណៈពិសេសនៃសហគមន៍កសិកម្មទំនើប ......18
៣.៣. ផលប្រយោជន៍នៃសហគមន៍កសិកម្មទំនើប ......19
៣.៤. រចនាសម្ព័ន្ធដឹកនាំនៃសហគមន៍កសិកម្មទំនើប ......20
៤. នីតិវិធីនៃការបង្កើតនិងការចុះបញ្ជីសហគមន៍កសិកម្មទំនើប ......21
៥. យន្តការគាំទ្រចំពោះសហគមន៍កសិកម្មទំនើប ......25
៥.១. ក្រុមប្រឹក្សាគោលនយោបាយសហគមន៍កសិកម្ម ......25
៥.២. មូលនិធិអភិវឌ្ឍសហគមន៍កសិកម្ម(ម.អ.ស) ......27
៦. កត្តាជោគជ័យនៃសហគមន៍កសិកម្មទំនើប ......27
៧. គម្រោងសាកល្បងនៃសហគមន៍កសិកម្មទំនើប ......28
៧.១. ភាពចាំបាច់នៃគម្រោងសាកល្បង ......28
៧.២. គោលបំណងជាក់លាក់ និងលទ្ធផលរំពឹងទុកពីគម្រោងសាកល្បង ......29
៧.៣. វិធីសាស្ត្រ និងវិសាលភាពនៃគម្រោងសាកល្បង ......31
៧.៤ ការវាយតម្លៃលើគម្រោងសាកល្បង ......32
៨. សេចក្តីសន្និដ្ឋាន ......33

## ជំពូកទី១

# កម្មវិធីគោលនយោបាយការលើកស្ទួយផលិតកម្មកសិកម្ម រកទីផ្សារ និងរក្សាលំនឹងថ្លៃកសិផល តាមរយៈកម្មវិធីហិរញ្ញប្បទាន

## ១. សេចក្តីផ្តើម

កម្មវិធីគោលនយោបាយអាទិភាពទី៥ ស្តីពី «យន្តការសម្របសម្រួល និងកម្មវិធីហិរញ្ញប្បទាន សំដៅលើកស្ទួយផលិតកម្ម រកទីផ្សារ និងរក្សាលំនឹងថ្លៃកសិផលសំខាន់ៗ ក្នុងកម្រិតសមរម្យ» តាមរយៈការដាក់ចេញនូវកញ្ចប់ថវិកាជាក់លាក់ ដោយចាប់ផ្តើមពីចំនួន ១០០ លានដុល្លារអាមេរិក និងអាចវិភាជថវិកាបន្ថែម ប្រសិនបើមានតម្រូវការចាំបាច់ គឺជាកម្មវិធីគោលនយោបាយជាតិដ៏សំខាន់មួយ។

ការអនុវត្តគោលនយោបាយ ប្រកបដោយប្រសិទ្ធភាពនឹងជួយ៖

- បង្កើនប្រាក់ចំណូលដល់ប្រជាកសិករ
- លើកទឹកចិត្តដល់កសិករក្នុងការងារផលិតកម្មកសិកម្ម
- រក្សាសន្តិសុខស្បៀងសម្រាប់សហគមន៍ និងក្នុងប្រទេស
- រក្សាលំនឹងនិរន្តរភាពផលិកម្មកសិកម្ម
- បង្កើនបរិមាណ និងគុណភាពនៃផលិតកម្មកសិកម្មសម្រាប់ផ្គត់ផ្គង់ការនាំចេញ។

កម្មវិធីគោលនយោបាយនេះ ផ្តោតលើកិច្ចអន្តរាគមន៍ឱ្យបានទាន់ពេលវេលា ក្នុងគោលដៅរក្សាស្ថិរភាពថ្លៃនៅរាល់រដូវប្រមូលផល លើផលិតផលកសិកម្មជាអាទិភាពមួយចំនួន។

កម្មវិធីគោលនយោបាយនេះ នឹងត្រូវអនុវត្តដោយក្រុមការងារចម្រុះសម្របសម្រួលអន្តរស្ថាប័នមួយ តាមរយៈវិធានការសំខាន់ៗមួយចំនួនដូចជា វិធានការទូទៅដែលមានឥទ្ធិពលលើថ្លៃកសិផល និងវិធានការគ្រប់គ្រងថ្លៃកសិផលផ្ទាល់។

## ២. វិធានការរក្សាស្ថិរភាពថ្លៃ

ការលើកស្ទួយផលិតកម្មកសិកម្ម រកទីផ្សារ និងរក្សាលំនឹងថ្លៃកសិផលជារឿងចាំបាច់។ យន្តការជាក់លាក់នឹងត្រូវដាក់ចេញ តាមរយៈវិធានការមួយចំនួនដោយផ្តោតទៅលើការទប់ស្កាត់មិនឱ្យមានការប្រែប្រួលតម្លៃខ្លាំង និងវិធានការខ្លះទៀតផ្តោតលើកិច្ចអន្តរាគមន៍ នៅពេលមានការប្រែប្រួលថ្លៃខ្លាំងកើតឡើង។ ប៉ុន្តែការជ្រើសរើសនិងអនុវត្តវិធានការណាមួយ អាស្រ័យលើការសម្រេចរបស់ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមការងារចម្រុះសម្របសម្រួលខ្សែច្រវាក់តម្លៃផលិតផលកសិកម្ម។

### ២.១ វិធានការទូទៅដែលមានឥទ្ធិពលលើថ្លៃកសិផល

ផ្អែកលើគោលការណ៍សេដ្ឋកិច្ចទីផ្សារសេរី ថ្លៃផលិតផលទាំងឡាយអាស្រ័យទៅលើបរិមាណនៃការផ្គត់ផ្គង់ និងតម្រូវការជាក់ស្តែង។ ក្នុងន័យនេះ វិធានការដែលមានប្រសិទ្ធភាពខ្ពស់ទៅលើថ្លៃ គឺការគ្រប់គ្រងការផ្គត់ផ្គង់ឱ្យឆ្លើយតបទៅនឹងតម្រូវការ។ កត្តាកំណត់ការផ្គត់ផ្គង់រួមមាន ផលិតកម្ម ការកែច្នៃ និងការនាំចូល។ ចំណែកតម្រូវការ មានតម្រូវការទីផ្សារក្នុងស្រុក និងការនាំចេញ។ ក្នុងស្មារតីបុរេសកម្ម ការថ្លឹងថ្លែងឱ្យមានតុល្យភាពរវាងការផ្គត់ផ្គង់និងតម្រូវការ គឺជាគន្លឹះនៃការរក្សាស្ថិរភាពថ្លៃ។ កិច្ចសម្រួលពាណិជ្ជកម្មមួយចំនួន រួមផ្សំនឹងការលុបបំបាត់សកម្មភាពបរិកប្បកម្ម (Speculation) ក៏ជាវិធានការទូទៅដែលមានឥទ្ធិពលលើថ្លៃកសិផលផងដែរ។ ក្រៅពីនេះ រដ្ឋនៅអាចរៀបចំជាប្រព័ន្ធស្តុក

បណ្តោះអាសន្ន សម្រាប់ធ្វើអន្តរាគមន៍លើថ្លៃកសិផលផ្ទាល់ក្នុងករណីចាំបាច់។ វិធានការនេះ នឹងអាចផ្សារភ្ជាប់ជាមួយហេដ្ឋារចនាសម្ព័ន្ធគាំទ្រដូចជា កន្លែងសម្ងួត កន្លែងប្រមូលផ្តុំ និងឃ្លាំងស្តុកជាដើម។ នៅមានយន្តការបុរេសកម្មផ្សេងៗទៀត ដូចជា ការអនុវត្តកិច្ចសន្យាផលិតកម្មកសិកម្ម ការអភិវឌ្ឍសហគមន៍កសិកម្មទំនើប ការកំណត់តំបន់គោលដៅសក្តានុពលសម្រាប់ផលិតផលកសិកម្ម ការគ្រប់គ្រងបច្ចេកវិទ្យាក្រោយប្រមូលផល ការសម្រួលចលនាកសិផលពីតំបន់មួយទៅតំបន់មួយដែលខ្វះខាត និងការរៀបចំឱ្យមានការធានារ៉ាប់រងកសិកម្ម ក៏ជាវិធានការទូទៅដែលមានឥទ្ធិពលលើថ្លៃផងដែរ។

### ២.២ វិធានការគ្រប់គ្រងថ្លៃកសិផលផ្ទាល់

វិធានការនេះ ជាវិធានការបន្ទាន់ និងបណ្តោះអាសន្ន សម្រាប់ប្រើតែក្នុងករណីចាំបាច់បំផុតតែប៉ុណ្ណោះ។ ក្នុងករណីនេះ រដ្ឋអាចកំណត់ថ្លៃពិតានខ្ពស់បំផុត (Ceiling Price) ជាពិសេសសម្រាប់តម្លៃកសិផលជាស្បៀង ឬអាចកំណត់តម្លៃទាបបំផុត (Minimum Floor Price) ដែលអនុញ្ញាតឱ្យធ្វើពាណិជ្ជកម្មស្របច្បាប់។

ក្រៅពីនេះ ក៏មានវិធានការអន្តរាគមន៍ថ្លៃផ្ទាល់ តាមរយៈការបញ្ចេញស្តុកយុទ្ធសាស្ត្រ ឬការបញ្ចេញថវិកាប្រមូលទិញដើម្បីទប់ទល់នឹងការធ្លាក់ថ្លៃ។ ការសម្រេចនេះត្រូវផ្អែកលើទស្សនវិស័យរយៈពេលវែង ដោយត្រូវធានាឱ្យបានថា កិច្ចអន្តរាគមន៍នឹងជួយសម្រាលស្ថានភាព ហើយជំរុញឱ្យតុល្យភាពនៃការផ្គត់ផ្គង់ និងតម្រូវការអាចវិលត្រឡប់មករកភាពប្រក្រតីវិញឱ្យបានឆាប់រហ័ស។

## ៣. ក្រុមការងារចម្រុះសម្របសម្រួល

ដើម្បីដឹកនាំសម្របសម្រួលការអនុវត្តកម្មវិធីនេះឱ្យទទួលបានជោគជ័យ រាជរដ្ឋាភិបាលបង្កើតឱ្យមានក្រុមការងារចម្រុះសម្របសម្រួលខ្សែច្រវាក់តម្លៃផលិតផលកសិកម្ម តាមសេចក្តីសម្រេចលេខ ១១២សសរ ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០២៣ ដោយមានការចូលរួមពីក្រសួងពាក់ព័ន្ធ និងស្ថាប័នឯកជនសំខាន់ៗមួយចំនួន (សេចក្តីសម្រេច មានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ)។

### ៣.១ សមាសភាព

សមាសភាពក្រុមការងារចម្រុះសម្របសម្រួលខ្សែច្រវាក់តម្លៃផលិតផលកសិកម្ម មានដូចតទៅ៖

| | | |
|---|---|---|
| ១ | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២ | តំណាងក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣ | តំណាងធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម | អនុប្រធាន |
| ៤ | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥ | អភិបាលរង នៃគណៈអភិបាលរាជធានី ខេត្ត ទទួលបន្ទុក | សមាជិក |
| ៦ | អគ្គលេខាធិការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិកអចិន្ត្រៃយ៍ |
| ៧ | មន្ត្រីជំនាញក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៨ | មន្ត្រីជំនាញក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៩ | តំណាងវិស័យឯកជនពាក់ព័ន្ធនឹងវិស័យកសិកម្ម | សមាជិក |
| ១០ | ប្រធានសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា | សមាជិក |

ដោយឡែក សមាសភាពជាក់ស្តែងនៃក្រុមការងារចម្រុះសម្របសម្រួលនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការគោលនយោបាយ

សេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសេចក្ដីសម្រេចលេខ ០៨១ សហវ.ស.ស.រ.គសហ ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងសមាសភាពក្រុមការងារចម្រុះសម្របសម្រួលខ្សែច្រវាក់តម្លៃផលិតផលកសិកម្ម (ឯកសារមានជូនភ្ជាប់ក្នុងឧបសម្ព័ន្ធ)។

### ៣.២ តួនាទី ភារកិច្ច និងការទទួលខុសត្រូវ

ក្រុមការងារចម្រុះសម្របសម្រួលនេះ មានភារកិច្ចដូចខាងក្រោម៖

- តាមដានការវិវឌ្ឍថ្លៃកសិផលលើទីផ្សារក្នុងនិងក្រៅប្រទេស ដើម្បីកំណត់មុខសញ្ញាកសិផលដែលអាចប្រឈមនឹងបញ្ហាប្រែប្រួលថ្លៃ
- វិភាគពីផលវិបាកនៃការប្រែប្រួលថ្លៃចំពោះអ្នកផលិត និងអ្នកប្រើប្រាស់ក្នុងប្រទេស
- ផ្អែកលើការវិភាគ កំណត់ថាផលិតផលកសិកម្មណាមួយដែលអាចជួបវិបត្តិ និងត្រូវការកិច្ចអន្តរាគមន៍ពីរាជរដ្ឋាភិបាល
- រៀបចំរបាយការណ៍ស្នើសុំការសម្រេចធ្វើអន្តរាគមន៍លើកសិផលណាមួយ ដែលអាចនឹងជួបវិបត្តិទៅប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុវត្តវិធានការអន្តរាគមន៍តាមគោលការណ៍សម្រេចរបស់ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រាយការណ៍អំពីវឌ្ឍនភាព និងលទ្ធផលនៃកិច្ចអន្តរាគមន៍ជូនប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមការចាំបាច់

- រៀបចំបង្កើតយន្តការ និងនីតិវិធីរួម (SOP) សម្រាប់ធ្វើអន្តរាគមន៍លើខ្សែប្រវាក់តម្លៃក្នុងករណីចាំបាច់ ដោយគោរពគោលការណ៍ទីផ្សារសេរីជាចម្បង
- បំពេញភារកិច្ចផ្សេងៗទៀត តាមការណែនាំរបស់ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ៤. លេខាធិការនៃក្រុមការងារចម្រុះសម្របសម្រួល

អគ្គលេខាធិការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាលេខាធិការនៃក្រុមការងារចម្រុះសម្របសម្រួលខ្សែប្រវាក់តម្លៃផលិតផលកសិកម្ម ដែលមានសេនាធិការមកពីអង្គភាពជំនាញតាមការចាំបាច់។

លេខាធិការ មានតួនាទី ភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម៖

- ជាជំនួយការផ្នែករដ្ឋបាលរបស់ក្រុមការងារ
- រៀបចំកិច្ចប្រជុំរបស់ក្រុមការងារអន្តរក្រសួង និងក្រុមការងាររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ប្រមូលព័ត៌មានពីស្ថាប័នពាក់ព័ន្ធជាសមាជិក
- សហការជាមួយក្រសួងពាណិជ្ជកម្ម វិស័យឯកជន និងតួអង្គពាក់ព័ន្ធដើម្បីតាមដាន វាយតម្លៃ លើវឌ្ឍនភាពទីផ្សារ និងតម្លៃកសិផលលើទីផ្សារទាំងក្នុងនិងក្រៅប្រទេស
- ជួយរៀបចំរបាយការណ៍ផ្សេងៗ
- ជួយរៀបចំសិក្ខាសាលា និងការប្រជុំពាក់ព័ន្ធនានា។

## ៥. សេចក្តីសន្និដ្ឋាន

កម្មវិធីគោលនយោបាយការលើកស្ទួយផលិតកម្មកសិកម្ម រកទីផ្សារ និងរក្សាលំនឹងថ្លៃកសិផល តាមរយៈកម្មវិធីហិរញ្ញប្បទាន ពិតជាមានសារសំខាន់ក្នុងការរក្សាស្ថិរភាពតម្លៃកសិផល និងជួយដល់សេដ្ឋកិច្ច និងប្រព័ន្ធមុខរបររបស់គ្រួសារកសិករ និងសន្តិសុខស្បៀង។ ដើម្បីអនុវត្តកម្មវិធីគោលនយោបាយនេះឱ្យទទួលបានជោគជ័យ ទាមទារឱ្យមានការចូលរួមពីស្ថាប័នជំនាញនិងអ្នកពាក់ព័ន្ធនានា។ លើសពីនេះទៀត ត្រូវអនុវត្តឱ្យមានភាពប្រទាក់ក្រឡាជាមួយគោលនយោបាយជាតិមួយចំនួនទៀតដូចជា ការដាក់ពង្រាយមន្ត្រីកសិកម្មឃុំ-សង្កាត់ ការអភិវឌ្ឍសហគមន៍កសិកម្មទំនើប និងគម្រោងអភិវឌ្ឍន៍នានាក្នុងការចូលរួមការកសាងខ្សែច្រវាក់ផលិតកម្មផ្សារភ្ជាប់នឹងទីផ្សារ៕

# ជំពូកទី២

# កម្មវិធីគោលនយោបាយការដាក់ពង្រាយមន្ត្រីកសិកម្ម ឃុំ-សង្កាត់

## ១. សេចក្តីផ្តើម

កម្មវិធីគោលនយោបាយការដាក់ពង្រាយមន្ត្រីកសិកម្មឃុំ-សង្កាត់ គឺជាកិច្ចខិតខំប្រឹងប្រែងមួយទៀតរបស់រាជរដ្ឋាភិបាល ក្នុងការបង្វិតសេវាឱ្យបានទៅជិតប្រជាពលរដ្ឋនៅមូលដ្ឋាន នៅគ្រប់ឃុំទាំងអស់នៅជនបទទូទាំងប្រទេស ដើម្បីជួយដល់គ្រួសារកសិករ ក្នុងការលើកស្ទួយផលិតភាពកសិកម្ម និងប្រាក់ចំណូល។

នៅប្រទេសកម្ពុជា មានឃុំដែលមានសកម្មភាពកសិកម្មចំនួន ១ ៥៥០ ក្នុងនោះឃុំភាគច្រើនជាឃុំសម្បូរផលិតកម្មស្រូវ(១០០០ឃុំ) ហើយដែលមានគ្រួសារជាកសិកម្មប្រមាណ ២ លានគ្រួសារ។

ដើម្បីឱ្យកសិករនៅគ្រប់ឃុំ-សង្កាត់ទទួលបានសេវាកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គ្រោងដាក់ពង្រាយមន្ត្រីកសិកម្មឃុំ-សង្កាត់ចំនួន ១ ៦០០នាក់ នៅទូទាំងប្រទេស។ តាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នៅដើមឆ្នាំ២០២៣ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសាកល្បងដាក់ពង្រាយមន្ត្រីកសិកម្មឃុំ-សង្កាត់ ចំនួន ១០នាក់ នៅ ១០ឃុំ ក្នុងស្រុកជើងព្រៃ ខេត្តកំពង់ចាម។

ដើម្បីពន្លឿនសេវាកសិកម្មដល់កសិករ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** បានណែនាំដ៏ខ្ពង់ខ្ពស់ ឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដាក់ពង្រាយមន្ត្រីកសិកម្មឃុំ-សង្កាត់ចំនួន ២៥០នាក់នៅឆ្នាំ២០២៣

ចំនួន ៨០០នាក់ នៅឆ្នាំ២០២៤ និង ៥៥០នាក់ នៅឆ្នាំ២០២៥ (ផែនការលម្អិតមានជូនភ្ជាប់ក្នុងឧបសម្ព័ន្ធ)។

## ២. គោលបំណង និងលទ្ធផលរំពឹងទុក

គោលបំណងចម្បងនៃកម្មវិធីគោលនយោបាយនេះ គឺដើម្បីបង្កើនប្រសិទ្ធភាពសេដ្ឋកិច្ចកសិកម្ម សម្រាប់គ្រួសារកសិករ តាមរយៈការជំរុញការអនុវត្តបច្ចេកទេសកសិកម្មមាននិរន្តរភាព ធន់នឹងការប្រែប្រួលអាកាសធាតុ និងការសាងប្រព័ន្ធផលិតកម្មផ្សារភ្ជាប់នឹងទីផ្សារ។

តាមរយៈការដាក់ពង្រាយមន្ត្រីកសិកម្មឃុំ-សង្កាត់ នៅគ្រប់ឃុំ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រំពឹងថា ការសម្របសម្រួល និងកិច្ចសហការរវាងថ្នាក់ជាតិនិងមូលដ្ឋាន នឹងកាន់តែរលូន និងជិតស្និទ្ធ។ កសិករនឹងទទួលបានភាពកក់ក្តៅ និងជំនឿចិត្តកាន់តែខ្ពស់ ចំពោះគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ជាក់ស្តែង កសិករនឹងទទួលបាន៖

- បច្ចេកទេសសមស្របសម្រាប់ការដាំដុះ ចិញ្ចឹមសត្វ ឬប្រមូលផលកសិកម្មទាំងមូលប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល
- ព័ត៌មានពីគ្រោះមហន្តរាយជាយថាហេតុ ដើម្បីបញ្ចៀសការខូចខាតជាអតិបរមា និងផ្តល់ដំណោះស្រាយបច្ចេកទេសទាន់ពេលចំពោះបញ្ហាប្រឈមផ្សេងៗនៅមូលដ្ឋាន
- ការពិគ្រោះយោបល់បន្ថែមសម្រាប់កាត់បន្ថយថ្លៃដើមផលិតកម្ម
- ព័ត៌មានទីផ្សារសម្រាប់តម្រង់ទិសផលិតកម្មរបស់ខ្លួន
- ការសម្របសម្រួលការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា និងព័ត៌មានជាក់លាក់ពីការអភិវឌ្ឍសហគមន៍កសិកម្មទំនើប។

ជាមួយគ្នានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងទទួលបាន៖

- ស្ថិតិ និងព័ត៌មានកសិកម្មកាន់តែសុក្រឹតសម្រាប់ប្រើប្រាស់ក្នុងការវិភាគ និងរៀបចំផែនការយុទ្ធសាស្ត្រ
- ព័ត៌មានស្តីពីបញ្ហាប្រឈមរបស់កសិករទាន់ពេលវេលា ដើម្បីដាក់វិធានការដោះស្រាយរហ័សប្រកបដោយប្រសិទ្ធភាព
- ភាពងាយស្រួលក្នុងការផ្តល់ព័ត៌មានពីគោលនយោបាយ និងផែនការដែលត្រូវអនុវត្តក្នុងវិស័យកសិកម្ម
- កសាងសហគមន៍កសិកម្ម ដោយផ្តោតលើការអភិវឌ្ឍសហគមន៍កសិកម្មទំនើបប្រកបដោយប្រសិទ្ធភាព។

## ៣. តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់មន្ត្រីកសិកម្មឃុំ-សង្កាត់

មន្ត្រីកសិកម្មឃុំ-សង្កាត់ មានតួនាទីជាអ្នកសម្របសម្រួលរវាងកសិករ និងភាគីពាក់ព័ន្ធ ដើម្បីទទួលបានសេវាគាំទ្រ និងដោះស្រាយបញ្ហាប្រឈមនានា។ មន្ត្រីកសិកម្មឃុំ-សង្កាត់ មានភារកិច្ចដូចតទៅ៖

- កំណត់បញ្ហាប្រឈមជាក់ស្តែងរបស់កសិករ តាមស្ថានភាពតំបន់
- រាយការណ៍បញ្ហាប្រឈមមកអង្គភាពជំនាញតាមឋានានុក្រម ដើម្បីដាក់ចេញនូវដំណោះស្រាយឱ្យបានទាន់ពេលវេលា
- គាំទ្រដល់ការអនុវត្តដំណោះស្រាយដែលបានផ្តល់ជូនកសិករ
- សម្របសម្រួលក្នុងគោលដៅផ្សារភ្ជាប់ និងពង្រឹងសហគមន៍កសិកម្មក្នុងខ្សែច្រវាក់ផលិតកម្មឆ្ពោះទៅទីផ្សារ
- ប្រមូលស្ថិតិកសិកម្ម។

ដើម្បីបំពេញតួនាទី ភារកិច្ច និងការទទួលខុសត្រូវខាងលើបានជោគជ័យ មន្ត្រីកសិកម្មឃុំ-សង្កាត់ ត្រូវការការគាំទ្រ និងពង្រឹងសមត្ថភាពជាប់ជានិច្ចពីមន្ត្រីជំនាញរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ជាគោលការណ៍ មន្ត្រីកសិកម្មឃុំ-សង្កាត់ម្នាក់ ទទួលខុសត្រូវការងារក្នុង១ឃុំ/សង្កាត់ ប៉ុន្តែក្នុងដំណាក់កាលដំបូង មន្ត្រីកសិកម្មឃុំ-សង្កាត់ម្នាក់ ទទួលខុសត្រូវ ២ឃុំ/សង្កាត់។

ដើម្បីបំពេញតួនាទីបានល្អ ទាមទារឱ្យមន្ត្រីកសិកម្មឃុំ-សង្កាត់ ធ្វើការសហការគ្នាជាក្រុមក្នុងពហុជំនាញនៅកម្រិតស្រុកគោលដៅ។

ភាពជោគជ័យរបស់មន្ត្រីកសិម្មឃុំ-សង្កាត់ នឹងត្រូវឆ្លុះបញ្ចាំង និងវាស់វែងតាមរយៈចំនួនកសិករដែលបានទទួលសេវាកម្មកសិកម្ម និងកំណើនប្រាក់ចំណូលរបស់គ្រួសារកសិករ។

## ៤. ការដឹកនាំ និងគ្រប់គ្រង

កម្មវិធីគោលនយោបាយការដាក់ពង្រាយមន្ត្រីកសិកម្មឃុំ-សង្កាត់ គឺជាកម្មវិធីជាតិមួយ ដែលអនុវត្តក្នុងក្របខ័ណ្ឌក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយសហការជាមួយរដ្ឋបាល ក្រុង ស្រុក និងឃុំ/សង្កាត់ និងអង្គភាពជំនាញពាក់ព័ន្ធដូចជា មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនសាទ និងការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថានជាដើម។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានតួនាទីក្នុងការជ្រើសរើសដាក់ពង្រាយ ការគាំទ្រដល់សកម្មភាពនៅតាមមូលដ្ឋាន ការពង្រឹងសមត្ថភាព និងការត្រួតពិនិត្យនិងវាយតម្លៃលើលទ្ធផលការងាររបស់មន្ត្រីកសិកម្មឃុំ-សង្កាត់។

មន្ត្រីកសិកម្មឃុំ-សង្កាត់ គឺជាមន្ត្រីក្របខ័ណ្ឌស្ថិតនៅក្រោមនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ៥. ថវិកា និងការគាំទ្រ

កម្មវិធីគោលនយោបាយការដាក់ពង្រាយមន្ត្រីកសិកម្មឃុំ-សង្កាត់ នឹងត្រូវប្រើប្រាស់ថវិការដ្ឋ។ ថវិកាគាំទ្ររួមមានដូចជា ប្រាក់បៀវត្សសម្រាប់មន្ត្រីក្របខ័ណ្ឌតាមរបបប្រាក់ឧបត្ថម្ភគ្រូបង្រៀន និងប្រាក់ឧបត្ថម្ភសម្រាប់ការធ្វើដំណើរតាមរបបបេសកកម្ម ចំនួន ១៦ ម៉ឺនរៀល/ខែ ស្របតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**។ ដោយឡែក ដើម្បីអនុវត្តការងារឱ្យមានប្រសិទ្ធភាព តម្រូវឱ្យមានការពង្រឹងសមត្ថភាព ការត្រួតពិនិត្យនិងវាយតម្លៃ ព្រមទាំងការផ្តល់មធ្យោបាយធ្វើដំណើរ និងសម្ភារៈមួយចំនួនដូចជា កុំព្យូទ័រ ឬបរិក្ខារបច្ចេកវិទ្យាព័ត៌មានផ្សេងៗ ដែលគួរប្រើប្រាស់ថវិកាហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍នានា។

## ៦. គោលការណ៍ និងនីតិវិធីនៃការជ្រើសរើស

ការដាក់ពង្រាយមន្ត្រីកសិកម្មឃុំ-សង្កាត់នៅឆ្នាំ២០២៣ និង២០២៤ គឺផ្តោតទៅលើឃុំគោលដៅដែលមានផលិតកម្មស្រូវជាចម្បង។ សម្រាប់ឆ្នាំ ២០២៤ ក្រសួងនឹងពិនិត្យពីអាទិភាពដាក់ពង្រាយមន្ត្រីកសិកម្មឃុំ-សង្កាត់ ដែលមានជំនាញសមស្របនឹងផលិតកម្មកសិកម្មចម្បងផ្សេងៗទៀត។ លើសពីនេះទៀត ក្រសួងនឹងដាក់ពង្រាយមន្ត្រីកសិកម្មឃុំ-សង្កាត់ ឱ្យមានជំនាញបច្ចេកទេសចម្រុះសម្រាប់ស្រុកនីមួយៗ។

ដើម្បីជ្រើសរើសមន្ត្រីកសិកម្មឃុំ-សង្កាត់ ប្រកបដោយប្រសិទ្ធភាព និងនិរន្តភាព អាទិភាពត្រូវបានផ្តល់ជូនដល់បេក្ខជនដែល៖

- ទទួលបានការអប់រំចាប់ពីថ្នាក់បរិញ្ញាបត្ររងឡើងទៅលើជំនាញកសិកម្ម និងាជំនាញពាក់ព័ន្ធ

- មានបទពិសោធន៍ការងារកសិកម្ម និងធ្វើការជាមួយកសិករក្នុងគម្រោងផ្សព្វផ្សាយកសិកម្ម
- មានលំនៅដ្ឋាននៅឃុំ ឬស្រុកគោលដៅ
- មានចំណង់ចំណូលចិត្តធ្វើការជាមួយកសិករនៅតាមមូលដ្ឋាន និងចេះធ្វើការជាក្រុម
- មានសក្តានុពលក្នុងការអភិវឌ្ឍខ្លួនឯង
- ជាកម្មសិក្សាការីយ៉ាងតិចចំនួន១ ឆ្នាំ។

## ៧. សេចក្តីសន្និដ្ឋាន

ភាពជោគជ័យនៃការអនុវត្តកម្មវិធីគោលនយោបាយការដាក់ពង្រាយមន្ត្រីកសិកម្មឃុំ-សង្កាត់ នឹងត្រូវវាស់វែងតាមរយៈចំនួនកសិករដែលបានទទួលសេវាគាំទ្រ និងកំណើននៃប្រាក់ចំណូលរបស់គ្រួសារកសិករ។

ការពង្រាយមន្ត្រីកសិកម្មឃុំ-សង្កាត់ នឹងជួយបំពេញបន្ថែមនូវកង្វះខាតធនធានមនុស្សផ្នែកកសិកម្មនៅមូលដ្ឋាន។ កម្មវិធីគោលនយោបាយនេះ ក៏នឹងជួយជំរុញការអនុវត្តការងារ របស់រាជរដ្ឋាភិបាលទាក់ទងនឹងវិស័យកសិកម្មឱ្យកាន់តែមានប្រសិទ្ធភាព និងបង្ខិតការផ្តល់សេវាកសិកម្មឱ្យដល់កសិករនៅតាមមូលដ្ឋានតែម្តង។ លើសពីនេះ មន្ត្រីកសិកម្មឃុំ-សង្កាត់ នឹងជួយទៅដល់អាជ្ញាធរមូលដ្ឋាន ជាពិសេសថ្នាក់ឃុំ ក្នុងការអនុវត្តសកម្មភាពចាំបាច់ក្នុងការជួយដល់កសិករ និងសហគមន៍កសិករ ដោយផ្សារភ្ជាប់នឹងបណ្តាញខ្សែច្រវាក់ផលិតកម្ម ដើម្បីបង្កើនប្រសិទ្ធភាពសេដ្ឋកិច្ចនៃផលិតកម្មកសិកម្ម កាត់បន្ថយថ្លៃដើមផលិតកម្ម និងមានភាពប្រកួតប្រជែងខ្ពស់ សំដៅលើកកម្ពស់ជីវភាព និងប្រាក់ចំណូលរបស់កសិករ។

គោលនយោបាយដ៏សំខាន់នេះ មិនអាចអនុវត្តតែឯងនោះឡើយ។ ពិតណាស់ វាជាយន្តការមួយដើម្បីគាំទ្រទៅដល់បណ្តាគោលនយោបាយនិងកម្មវិធីដទៃទៀត របស់រាជរដ្ឋាភិបាលលើវិស័យកសិកម្ម ដូចជា ការអភិវឌ្ឍសហគមន៍កសិកម្មទំនើប ការរក្សាស្ថិរភាពថ្លៃកសិផល និងការរក្សានិរន្តរភាពនៃបរិស្ថានកសិកម្ម ការរក្សាធនធានព្រៃឈើ និងធនធានផលផលជាដើម។

## ជំពូកទី៣

# កម្មវិធីគោលនយោបាយការអភិវឌ្ឍសហគមន៍ កសិកម្មធំនើប

### ១. សេចក្តីផ្តើម

សហគមន៍កសិកម្មគឺជាសហគ្រាសសេដ្ឋកិច្ចកសិកម្ម ដែលមានប្រជាកសិករខ្លួនឯងផ្ទាល់រួមគ្នាធ្វើជាម្ចាស់កម្មសិទ្ធិ។ សហគមន៍កសិកម្មប្រភេទនេះគឺជានីតិបុគ្គលឯកជន បង្កើតឡើងដោយរូបវន្តបុគ្គលមួយក្រុម ដែលមានមុខរបរចម្បងពាក់ព័ន្ធនឹងវិស័យកសិកម្ម តាមការស្ម័គ្រចិត្ត រួមគ្នាបង្កើតដើមទុន និងរួមគ្នាគ្រប់គ្រងតាមលក្ខណៈប្រជាធិបតេយ្យ ដើម្បីពង្រឹងសមត្ថភាពផ្នែកផលិតកម្មកសិកម្ម កសិ-ពាណិជ្ជកម្ម កសិ-ឧស្សាហកម្ម និងសេវាកម្មពាក់ព័ន្ធនឹងផលិតកម្មកសិកម្ម សំដៅលើកកម្ពស់ជីវភាពរបស់សមាជិក និងចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ ស្របតាមគោលការណ៍គ្រឹះទាំង៧ របស់សម្ព័ន្ធសហករណ៍អន្តរជាតិ។

- ចាប់ពីឆ្នាំ២០០៣ ដល់ ឆ្នាំ២០២២ សហគមន៍កសិកម្មនៅកម្ពុជាសរុបមានចំនួន ១ ២៥១ សហគមន៍
- សមាជិកសរុប ១៧០ ២០៨នាក់ (៦៣% ជាស្ត្រី) ស្មើនឹង ៥,៩% នៃចំនួនកសិករសរុបទូទាំងប្រទេស
- តម្លៃភាគហ៊ុនសរុប ដែលជាការវិនិយោគផ្ទាល់របស់សមាជិក មានចំនួន ៥១ ពាន់លានរៀល (ប្រមាណជា ១២,៨ លានដុល្លារ) ស្មើនឹង ៧៣ដុល្លារ ក្នុងសមាជិកមួយនាក់

- បូករួមនឹងប្រាក់ចំណេញរក្សាទុក អំណោយរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ទុនបង្វិលសហគមន៍សរុបមានចំនួន ១០៤ ពាន់លានរៀល (ប្រមាណ ២៦ លានដុល្លារ) ឬ ប្រហែល ២ ម៉ឺនដុល្លារ ក្នុងមួយសហគមន៍
- តាមការវាយតម្លៃឆ្នាំ២០២២ សហគមន៍កសិកម្មខ្លាំងមាន ១៧,៥% មធ្យម ៦៦% និងខ្សោយ ១៦,៥%។

## ២. បញ្ហាប្រឈមនៃសហគមន៍កសិកម្មបច្ចុប្បន្ន

នាពេលបច្ចុប្បន្ននេះ សហគមន៍កសិកម្មកំពុងជួបប្រទះបញ្ហាប្រឈមធំៗចំនួន៥ គឺ៖

- កង្វះដើមទុន និងទុនបង្វិលសម្រាប់អាជីវកម្មរបស់ខ្លួន
- កង្វះធនធានមនុស្សក្នុងការដឹកនាំគ្រប់គ្រងប្រកបដោយវិជ្ជាជីវៈ និងបច្ចេកទេសផលិតកម្មខ្ពស់
- ថ្លៃដើមផលិតកម្មខ្ពស់ និងមិនមានសមត្ថភាពប្រកួតប្រជែងនៅលើទីផ្សារ ដោយសារសមាជិកម្នាក់ៗនៅបន្តធ្វើផលិតកម្មរៀងៗខ្លួន ទិញធាតុចូល និងលក់កសិផលដាច់ដោយឡែកពីគ្នា
- មិនទាន់មានសមត្ថភាពចាប់យកឱកាសទីផ្សារ និងមិនអាចឆ្លើយតបទៅនឹងតម្រូវការទីផ្សារបានទូលំទូលាយ ដោយសារបញ្ហាប្រឈមទាំងខាងផ្នែកបរិមាណ គុណភាព និងតម្លៃ
- ងាយរងគ្រោះពីហានិភ័យនៃការប្រែប្រួលអាកាសធាតុ។

បន្ថែមពីនេះ ក៏នៅមានបញ្ហាប្រឈមផ្សេងទៀតដែលសហគមន៍បច្ចុប្បន្នកំពុងជួបប្រទះផងដែរ ដូចជា៖

- កង្វះការតម្រង់ទិស និងកិច្ចសម្របសម្រួលរួមនៅក្នុងចំណោមសមាជិកសហគមន៍
- ផលិតកម្មមានទំហំតូច ស្ថិតនៅដាច់ដោយឡែកៗពីគ្នា មិនទាន់មានសមាហរណកម្ម និងមិនមាននិរន្តរភាពក្នុងការផ្គត់ផ្គង់តម្រូវការទីផ្សារ
- ទំនាស់ផលប្រយោជន៍រវាងសហគមន៍ និងសមាជិក
- កង្វះទ្រព្យសម្បត្តិរួម និងសហគមន៍មានប្រាក់ចំណូលតិចតួច
- កង្វះសេវាកម្មគាំទ្រពីសហគមន៍ចំពោះសមាជិក និងកង្វះទំនុកចិត្តពីសមាជិកមកលើសហគមន៍
- កង្វះភាពជាម្ចាស់ក្នុងការដឹកនាំគ្រប់គ្រងសហគមន៍។

ការកែទម្រង់សហគមន៍កសិកម្មឱ្យមានសមាហរណកម្មខ្ពស់ គឺជាទំនើបកម្មដ៏ចាំបាច់ ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ ជាពិសេសបង្កើនភាពប្រកួតប្រជែងនៅក្នុងផ្នែកផលិតកម្មនៃខ្សែច្រវាក់ តម្លៃកសិកម្មរបស់កម្ពុជា សំដៅលើកកម្ពស់ជីវភាពកសិករ ធានាសន្តិសុខស្បៀង និងចូលរួមចំណែកប្រែក្លាយប្រទេសកម្ពុជា ឱ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០។

## ៣. សហគមន៍កសិកម្មទំនើប

«សហគមន៍កសិកម្មទំនើប» គឺជាចក្ខុវិស័យនៃការអនុវត្តផលិតកម្មកសិកម្មរួមគ្នាក្នុងទ្រង់ទ្រាយធំ នៅក្នុងវិស័យកសិកម្ម ដែលជាផ្នែកមួយនៃកម្មវិធីគោលនយោបាយអាទិភាពទី៦ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា និងគ្រោងដាក់ឱ្យអនុវត្តនៅក្នុងឆ្នាំ២០២៣ នេះ។

## ៣.១. គោលបំណង

ប្រែក្លាយវិស័យកសិកម្មកម្ពុជាពីលក្ខណៈគ្រួសារឱ្យទៅជាសហគ្រាសសេដ្ឋកិច្ចកសិកម្មដ៏រឹងមាំ មានសមាហរណកម្មខ្ពស់ មានសេដ្ឋកិច្ចមាត្រដ្ឋាន (Economies of Scale) និងមានសមត្ថភាពប្រកួតប្រជែងទាំងបរិមាណ និងគុណភាព។

## ៣.២. លក្ខណៈពិសេសនៃសហគមន៍កសិកម្មទំនើប

លក្ខណៈពិសេសរបស់សហគមន៍កសិកម្មទំនើប តម្រូវឱ្យកសិករជាសមាជិកត្រូវធ្វើផលិតកម្មកសិកម្មរួមគ្នា និងមានការគ្រប់គ្រងរួមប្រកបដោយវិជ្ជាជីវៈខ្ពស់ដើម្បីបង្កើនសមត្ថភាពប្រកួតប្រជែង នៅលើទីផ្សារ ទាំងខាងផ្នែកបរិមាណ គុណភាព ថ្លៃ និងនិរន្តរភាពនៃការផ្គត់ផ្គង់ ពោល គឺទិញរួម ផលិតរួម លក់រួម និងគ្រប់គ្រងរួមដោយសហគមន៍ មុននឹងធ្វើការបែងចែកប្រាក់ចំណេញទៅតាមសមាមាត្រនៃភាគហ៊ុនរបស់សមាជិកម្នាក់ៗ។ ប្រជាកសិករទាំងអស់ដែលមានចំណាប់អារម្មណ៍ អាចចូលរួមដោយស្ម័គ្រចិត្ត ជាមួយសហគមន៍កសិកម្មទំនើប តាមជម្រើសដូចខាងក្រោម៖

**ជម្រើសទី១៖** សហគមន៍កសិកម្មទំនើបជួលដីផលិតកម្ម ឬម៉ៅដំណាំរបស់កសិករជាសមាជិក ដើម្បីយកទៅធ្វើផលិតកម្មកសិកម្មរួមគ្នា។ កសិករជាសមាជិកទទួលបាន៖

- ចំណូលពីថ្លៃឈ្នួលមូលដ្ឋាននៃការជួលដីផលិតកម្ម ឬចម្ការដំណាំរបស់ខ្លួន

- ភាគលាភបន្ថែមពីប្រាក់ចំណេញ របស់សហគមន៍ ទៅតាមសមាមាត្រនៃភាគហ៊ុនរបស់ខ្លួន ដែលត្រូវបានកំណត់ដោយទំហំដី ឬដំណាំក្នុងចម្ការ ដែលបានជួល ឬម៉ៅឱ្យសហគមន៍
- ប្រាក់កម្រៃបន្ថែមពីថ្លៃឈ្នួលពលកម្មពីសហគមន៍។

**<u>ជម្រើសទី២</u>**៖ កសិករជាសមាជិកយកការប្រើប្រាស់ដីផលិតកម្ម ឬដំណាំរបស់ខ្លួន ដាក់ចូលធ្វើជាភាគហ៊ុននៅក្នុងសហគមន៍កសិកម្មទំនើប ដើម្បីយកទៅធ្វើផលិតកម្មកសិកម្មរួមគ្នា។ កសិករជាសមាជិកទទួលបាន៖

- ភាគលាភពីប្រាក់ចំណេញរបស់សហគមន៍ ទៅតាមសមាមាត្រនៃភាគហ៊ុនរបស់ខ្លួន ដែលត្រូវបានកំណត់ដោយទំហំដីឬដំណាំក្នុងចម្ការដែលបានដាក់ចូលជាភាគហ៊ុន
- ប្រាក់កម្រៃបន្ថែមពីថ្លៃឈ្នួលពលកម្មពីសហគមន៍កសិកម្មទំនើប។

សមាជិកភាព និងការចូលរួមជាមួយសហគមន៍កសិកម្មទំនើប ត្រូវធ្វើឡើងដោយឈរលើគោលការណ៍ស្ម័គ្រចិត្ត និងបើកចំហដោយគ្មានការរើសអើង។ រាល់ការជួល ឬការដាក់ដីផលិតកម្មជាភាគហ៊ុននៅក្នុងសហគមន៍នឹងមិនប៉ះពាល់ដល់កម្មសិទ្ធិលើដីធ្លីរបស់កសិករជាសមាជិកឡើយ។ សមាជិកម្នាក់ៗមានសិទ្ធិសុំលាឈប់ពីសមាជិកភាព និងដកដីផលិតកម្ម ឬដំណាំរបស់ខ្លួនចេញពីសហគមន៍បាន ដោយត្រូវអនុលោមទៅតាមលក្ខន្តិកៈនៃសហគមន៍។

### ៣.៣. ផលប្រយោជន៍នៃសហគមន៍កសិកម្មទំនើប

ធៀបនឹងសហគមន៍កសិកម្មបច្ចុប្បន្ន សហគមន៍កសិកម្មទំនើប នឹងទទួលបានផលប្រយោជន៍ដូចជា៖

- ការលើកកម្ពស់អំណាចចរចាទីផ្សារទាំងក្នុងការទិញធាតុចូល និងការលក់កសិផលរបស់សហគមន៍
- ការកាត់បន្ថយថ្លៃដើមផលិតកម្ម និងបង្កើនប្រាក់ចំណេញឱ្យបានជាអតិបរមា តាមរយៈអត្ថប្រយោជន៍ដែលទទួលបានពីសេដ្ឋកិច្ចមាត្រដ្ឋាន (Economies of Scale)
- ការទទួលបានការគាំទ្របច្ចេកទេស សម្ភារៈ ហេដ្ឋារចនាសម្ព័ន្ធ បច្ចេកវិទ្យា និងការប្រឹក្សាយោបល់លើផលិតកម្មកសិកម្ម និងការគ្រប់គ្រងមុខជំនួញប្រកបដោយវិជ្ជាជីវៈខ្ពស់
- ការទទួលបានទីផ្សារកសិផលទូលំទូលាយ និងមានសមត្ថភាពអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា
- ការទទួលបានការគាំទ្រលើទុនបង្វិល និងប្រាក់កម្ចីសម្រាប់ប្រតិបត្តិការ និងការពង្រីកអាជីវកម្ម
- ការកាត់បន្ថយហានិភ័យពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ
- ការធ្វើឱ្យប្រសើរឡើងនៃជីវភាពរបស់កសិករជាសមាជិក។

## ៣.៤. រចនាសម្ព័ន្ធដឹកនាំនៃសហគមន៍កសិកម្មទំនើប

សហគមន៍កសិកម្មទំនើបត្រូវបានដឹកនាំ និងតម្រង់ទិសដោយក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យ។ ចំណែកឯការងារប្រចាំថ្ងៃ និងការប្រតិបត្តិការផលិតកម្មនិងអាជីវកម្មរបស់សហគមន៍ ត្រូវគ្រប់គ្រងដោយនាយកប្រតិបត្តិ និងគណៈគ្រប់គ្រងមួយដាច់ដោយឡែក ដែលមានជំនាញវិជ្ជាជីវៈ និងបទពិសោធន៍ច្បាស់លាស់។ សហគមន៍ក៏អាចមានក្រុមទីប្រឹក្សាដែលមានជំនាញពាក់ព័ន្ធការងារកសិកម្ម និងជំនាញពាក់ព័ន្ធផ្សេងទៀត

សម្រាប់ជួយគាំទ្រផងដែរ។ រចនាសម្ព័ន្ធសហគមន៍កសិកម្មទំនើប ត្រូវបានបង្ហាញនៅក្នុងដ្យាក្រាម ដូចខាងក្រោម៖

**រចនាសម្ព័ន្ធសហគមន៍កសិកម្មទំនើប**




- បន្ទាត់ ---------- ការផ្តល់ប្រឹក្សាយោបល់ មិនគ្រប់គ្រងដឹកនាំឡើយ
- បន្ទាត់ _______ ការដឹកនាំនិងគ្រប់គ្រងផ្ទាល់

## ៤. នីតិវិធីនៃការបង្កើតនិងការចុះបញ្ជីសហគមន៍កសិកម្មទំនើប

ក្របខ័ណ្ឌគតិយុត្តនៃការបង្កើត និងចុះបញ្ជីសហគមន៍កសិកម្ម ត្រូវអនុលោមតាមប្រកាសលេខ ១៦៦ ប្រក. កសក ស្តីពីគោលការណ៍ណែនាំនីតិវិធីនៃការបង្កើតនិងការចុះបញ្ជីសហគមន៍កសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨ និងច្បាប់ស្តីពីសហគមន៍កសិកម្ម ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៣។ ដើម្បីគាំទ្រដល់ការកសាងសហគមន៍កសិកម្មទំនើប

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គ្រោងអនុវត្តតាមជំហានជាយុទ្ធសាស្ត្រចំនួន៥ ដូចខាងក្រោម៖

## ▪ ជំហានទី១៖ ផ្សព្វផ្សាយគោលគំនិតស្តីពីសហគមន៍កសិកម្មទំនើប និងអង្កេតទស្សនៈរបស់កសិករ

ដើម្បីអនុវត្តជំហានទី១នេះ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម ដែលជាអង្គភាពមានសមត្ថកិច្ច ត្រូវអនុវត្តសកម្មភាពសំខាន់ៗ មួយចំនួនដូចខាងក្រោម៖

- សិក្សាកំណត់បញ្ហាប្រឈមជាក់ស្តែងរបស់កសិករនៅក្នុងខ្សែច្រវាក់តម្លៃផលិតកម្មកសិកម្មជាក់លាក់ណាមួយ
- កំណត់តម្រូវការទីផ្សារ និងសក្តានុពលផលិតកម្មរបស់ សហគមន៍កសិកម្មទំនើប
- ក្នុងករណីសហគមន៍កសិកម្មទំនើបអាចផ្តល់ដំណោះស្រាយ ដល់បញ្ហាប្រឈមខាងលើបាន ទើបផ្សព្វផ្សាយទស្សនទានស្តីពីការអភិវឌ្ឍសហគមន៍កសិកម្មទំនើបដល់ប្រជាកសិករ ដើម្បីប្រមូលកសិករចូលរួម។

## ▪ ជំហានទី២ ៖ បង្កើតគណៈកម្មការសម្រាប់បង្កើតសហគមន៍កសិកម្មទំនើប

ក្នុងជំហានទី២នេះ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម ត្រូវអនុវត្តសកម្មភាពសំខាន់ៗដូចខាងក្រោម៖

- សម្របសម្រួលកសិករដែលមានការចាប់អារម្មណ៍ ដើម្បីបង្កើតជាគណៈកម្មការរៀបចំសហគមន៍កសិកម្មទំនើប

- សិក្សាសមិទ្ធិលទ្ធភាពសេដ្ឋកិច្ច របស់សហគមន៍កសិកម្មទំនើប (Feasibility Study) ដើម្បីកំណត់ទំហំអប្បបរមាដែលអាចទទួលបានសេដ្ឋកិច្ចមាត្រដ្ឋាន
- សម្របសម្រួលប្រមូលសមាជិកឱ្យបានគ្រប់ ទៅតាមទំហំអប្បបរមាដែលអាចទទួលបានសេដ្ឋកិច្ចមាត្រដ្ឋាន
- បណ្តុះបណ្តាលស្តីពីលក្ខន្តិកៈគំរូ និងបទបញ្ជាផ្ទៃក្នុងគំរូ និងសម្រប-សម្រួលរៀបចំសេចក្តីព្រាងលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍កសិកម្មទំនើប
- សម្របសម្រួលរៀបចំផែនការផលិតកម្មអាជីវកម្ម (Business Plan)
- កំណត់ទុនវិនិយោគដំបូង និងជួយជ្រោមជ្រែងដាក់ទុនវិនិយោគ។

▪ **ជំហានទី៣ ៖ រៀបចំមហាសន្និបាតកំណើតដំបូង**

ដើម្បីអនុវត្តជំហានទី៣ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម ត្រូវសម្របសម្រួលជាមួយគណៈកម្មការបង្កើតសហគមន៍កសិកម្មទំនើប ដើម្បីអនុវត្តសកម្មភាពសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- រៀបចំភស្តុភាកម្មសម្រាប់រៀបចំដំណើរការ មហាសន្និបាតកំណើតលើកដំបូង
- រៀបចំកម្មវិធីមហាសន្និបាតកំណើតដំបូង
- សម្របសម្រួលដំណើរការមហាសន្និបាតកំណើតដំបូង
- សម្របសម្រួលដំណើរការបោះឆ្នោត ដើម្បីអនុម័តយល់ព្រមលើលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង សមាសភាពក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យ ផែនការមុខជំនួញ តម្លៃភាគហ៊ុន និងប្រាក់

សមាជិកភាព ព្រមទាំងអនុម័តលើកិច្ចការពាក់ព័ន្ធផ្សេងទៀតរបស់សហគមន៍កសិកម្មទំនើប

- សម្របសម្រួលកត់ត្រានូវដំណើរការ និងលទ្ធផលរបស់មហាសន្និបាតកំណើតដំបូង និងរៀបចំរបាយការណ៍មហាសន្និបាតកំណើតដំបូង។

▪ **ជំហានទី៤ ៖ រៀបចំឯកសារចាំបាច់សម្រាប់ចុះបញ្ជីផ្លូវការ**

ក្នុងជំហានទី៤ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មត្រូវសម្របសម្រួលជាមួយគណៈកម្មការបង្កើតសហគមន៍កសិកម្មទំនើប ព្រមទាំងសហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសាមី ដើម្បីរៀបចំឯកសារចាំបាច់មួយចំនួនសម្រាប់ដាក់ជូនអង្គភាពចុះបញ្ជី ដែលមានដូចខាងក្រោម៖

- ចងក្រងរបាយការណ៍មហាសន្និបាតកំណើតដំបូង
- ពិនិត្យផែនការអាជីវកម្មមុខជំនួញរបស់សហគមន៍កសិកម្មទំនើប
- ចងក្រងលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងសហគមន៍កសិកម្មទំនើប
- រៀបចំបញ្ជីសមាសភាពក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យរបស់សហគមន៍កសិកម្មទំនើប
- ចងក្រងបញ្ជីឈ្មោះកសិករស្ម័គ្រចិត្តចូលជាសមាជិក ចំនួនភាគហ៊ុន និងប្រាក់សមាជិកភាព
- រៀបចំគំរូហត្ថលេខា ឬស្នាមមេដៃស្ដាំរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬអ្នកមានសិទ្ធិតំណាងឱ្យសហគមន៍កសិកម្មទំនើប។

▪ **ជំហានទី៥៖ រៀបចំគណៈគ្រប់គ្រងរបស់សហគមន៍កសិកម្មទំនើប**

ក្នុងជំហានទី៥ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មត្រូវសម្រប សម្រួលជាមួយក្រុមប្រឹក្សាភិបាលសហគមន៍កសិកម្មទំនើប ដើម្បីជ្រើសរើស គណៈគ្រប់គ្រងរបស់សហគមន៍កសិកម្មទំនើបដូចជា៖

- ជ្រើសរើសនាយកប្រតិបត្តិដែលមានគុណវុឌ្ឍិនិងវិជ្ជាជីវៈខ្ពស់
- ជ្រើសរើសគណនេយ្យករ
- ជ្រើសរើសអ្នកគ្រប់គ្រងប្រតិបត្តិការផលិតកម្ម
- ជ្រើសរើសបុគ្គលិកជំនាញផ្សេងៗទៀតតាមការចាំបាច់។

## ៥. យន្តការគាំទ្រចំពោះសហគមន៍កសិកម្មទំនើប

ដើម្បីអភិវឌ្ឍសហគមន៍កសិកម្មទំនើបឱ្យទទួលបានជោគជ័យ និងមាន និរន្តរភាព រាជរដ្ឋាភិបាលបានដាក់ចេញនូវយន្តការគាំទ្រថ្នាក់ជាតិមួយចំនួន ដូចជា៖

### ៥.១. ក្រុមប្រឹក្សាគោលនយោបាយសហគមន៍កសិកម្ម

ក្រុមប្រឹក្សាគោលនយោបាយសហគមន៍កសិកម្ម គឺជាយន្តការថ្នាក់ ជាតិថ្មីមួយដែលត្រូវបានបង្កើតឡើង ដើម្បីជួយរៀបចំក្របខ័ណ្ឌគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ និងការតម្រង់ទិសដៅសម្រាប់ ការអភិវឌ្ឍសហគមន៍កសិកម្មទំនើបនៅកម្ពុជា។

តួនាទីនិងភារកិច្ចរបស់ក្រុមប្រឹក្សាគោលនយោបាយសហគមន៍ កសិកម្ម មានដូចជា៖

- សិក្សាស្រាវជ្រាវ និងពិគ្រោះយោបល់ ដើម្បីរៀបចំលិខិតបទដ្ឋាន គតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការ

សកម្មភាពពាក់ព័ន្ធនឹងការអភិវឌ្ឍសហគមន៍កសិកម្ម ដោយអនុលោមទៅតាមលក្ខខណ្ឌសេដ្ឋកិច្ចសង្គម

- លើកសំណើជូនរាជរដ្ឋាភិបាល ដើម្បីស្នើសុំការសម្រេច ឬកែសម្រួលលើគោលនយោបាយជាតិស្តីពីការអភិវឌ្ឍសហគមន៍កសិកម្ម
- តាមដានត្រួតពិនិត្យនិងវាយតម្លៃលើការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធីការងារសម្រាប់ការអភិវឌ្ឍសហគមន៍កសិកម្ម
- កំណត់ទិសដៅក្នុងការពង្រឹងសមត្ថភាព និងការជំរុញកិច្ចសហប្រតិបត្តិការរបស់សហគមន៍កសិកម្ម ជាមួយផ្នែកឯកជន និងដៃគូអភិវឌ្ឍន៍នានា
- សម្របសម្រួលរវាងស្ថាប័នរដ្ឋពាក់ព័ន្ធ ផ្នែកឯកជន និងស្ថាប័នហិរញ្ញវត្ថុ ដើម្បីជំរុញ និងទ្រទ្រង់ដល់ប្រតិបត្តិការរបស់សហគមន៍កសិកម្ម
- ចេញសេចក្តីសម្រេចឬសេចក្តីណែនាំដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ រាជធានី ខេត្ត ក្នុងការដាក់ឱ្យអនុវត្តកម្មវិធីការងារក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដែលពាក់ព័ន្ធនឹងគោលនយោបាយផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពអភិវឌ្ឍសហគមន៍កសិកម្ម
- ដោះស្រាយបញ្ហាឬឧបសគ្គដែលរាំងស្ទះដល់ការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពអភិវឌ្ឍសហគមន៍កសិកម្ម
- ធ្វើរបាយការណ៍ប្រចាំឆ្នាំជូនរាជរដ្ឋាភិបាលអំពីលទ្ធផលនៃការអភិវឌ្ឍសហគមន៍កសិកម្ម

- បំពេញមុខងារពាក់ព័ន្ធផ្សេងទៀតដែលគាំទ្រដល់គោលនយោបាយ អភិវឌ្ឍសហគមន៍កសិកម្មក្រោមវិសាលភាពនៃច្បាប់ស្តីពីសហគមន៍កសិកម្ម។

## ៥.២. មូលនិធិអភិវឌ្ឍសហគមន៍កសិកម្ម(ម.អ.ស)

មូលនិធិអភិវឌ្ឍសហគមន៍កសិកម្ម គឺជាយន្តការថ្នាក់ជាតិថ្មីមួយទៀត ដែលស្ថិតនៅការគ្រប់គ្រងផ្ទាល់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីប្រើប្រាស់ក្នុងក្របខ័ណ្ឌនៃការគាំទ្រ និងការអភិវឌ្ឍសហគមន៍កសិកម្មទំនើប នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ មូលនិធិអភិវឌ្ឍនេះ នឹងត្រូវប្រើប្រាស់ក្នុងសកម្មភាពដូចខាងក្រោម៖

- ផ្តល់ជំនួយហិរញ្ញវត្ថុដល់សហគមន៍កសិកម្ម ឬសហភាពសហគមន៍កសិកម្ម ដើម្បីធ្វើជាដើមទុនសម្រាប់ប្រតិបត្តិការមុខរបររបស់ខ្លួន
- ផ្តល់ជំនួយហិរញ្ញវត្ថុដល់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាដើម្បីគាំទ្រដល់ដំណើរការរបស់ខ្លួន
- គាំទ្រដល់សហគមន៍កសិកម្ម ឬសហភាពសហគមន៍កសិកម្មលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងទីផ្សារដែលបាន អនុម័តយល់ព្រមដោយក្រុមប្រឹក្សាភិបាល ម.អ.ស.
- ទ្រទ្រង់ដំណើរការរៀបចំបង្កើតសហគមន៍កសិកម្ម ឬសហភាពសហគមន៍កសិកម្មនៅតាមបណ្តារាជធានីខេត្ត ដែលមានតម្រូវការចាំបាច់របស់ប្រជាកសិករ។

# ៦. កត្តាជោគជ័យនៃសហគមន៍កសិកម្មទំនើប

ភាពជោគជ័យ និងនិរន្តរភាពនៃសហគមន៍កសិកម្មទំនើប នឹងត្រូវកំណត់ដោយកត្តាគន្លឹះមួយចំនួនដូចជា៖

- ធនធានមនុស្សប្រកបដោយគុណវុឌ្ឍិ និងកម្រិតវិជ្ជាជីវៈខ្ពស់
- ប្រព័ន្ធគ្រប់គ្រងច្បាស់លាស់ និងផែនការអាជីវកម្មរឹងមាំ
- ទំនុកចិត្ត និងភាពជឿជាក់ខ្ពស់ពីសំណាក់សមាជិកសហគមន៍ និងដៃគូពាក់ព័ន្ធ
- ភាពជាម្ចាស់លើដំណើរការអាជីវកម្មប្រកបដោយសហគ្រិនភាព ភាពស្មោះត្រង់ នវានុវត្តន៍ និងការប្រកួតប្រជែង
- សហគមន៍មានវិសាលភាពធំ និងមានសេដ្ឋកិច្ចមាត្រដ្ឋាន
- និរន្តរភាពខាងផ្នែកសេដ្ឋកិច្ច និងមូលធនរឹងមាំ
- ភាពទាក់ទាញ និងការចូលរួមគាំទ្រទូលំទូលាយពីប្រជាកសិករនៅក្នុងវិស័យកសិកម្មទាំងមូល។

កត្តាគន្លឹះខាងលើសុទ្ធតែជាចំណុចខ្វះខាត ដែលកើតឡើងចំពោះការធ្វើកសិកម្មជាលក្ខណៈគ្រួសារ ឬសូម្បីតែការវិនិយោគជាលក្ខណៈឯកជនខ្នាតធំ ពិបាកសម្រេចបាន។ ដើមទុនចាប់ផ្តើមដំបូងគឺជាកត្តាកំណត់ចម្បង ដែលមូលនិធិអភិវឌ្ឍសហគមន៍កសិកម្ម ត្រូវវិនិយោគទៅក្នុងសហគមន៍ជាការចាំបាច់។ ប៉ុន្តែ សហគមន៍កសិកម្មទំនើបដែលបានបង្កើតឡើងរួចហើយ នឹងមាននិរន្តរភាពសេដ្ឋកិច្ចគ្រប់គ្រាន់ ក្នុងការសងត្រឡប់មកមូលនិធិអភិវឌ្ឍសហគមន៍កសិកម្មវិញ នូវដើមទុនវិនិយោគដំបូងទាំងនេះផងដែរ។

## ៧. គម្រោងសាកល្បងនៃសហគមន៍កសិកម្មទំនើប

### ៧.១. ភាពចាំបាច់នៃគម្រោងសាកល្បង

សហគមន៍កសិកម្មទំនើបមានទំហំធំ ពាក់ព័ន្ធនឹងកសិករច្រើនគ្រួសារ និងមានចក្ខុវិស័យគ្របដណ្តប់ស្ទើរតែគ្រប់ទីកន្លែងនៅទូទាំងប្រទេសកម្ពុជា។ ចំណែកឯការធ្វើផលិតកម្មកសិកម្មរួមគ្នា និងការរៀបចំឱ្យមានអ្នកគ្រប់គ្រងរួម

គឺជាទម្រង់ថ្មីដែលមិនធ្លាប់បានធ្វើក្នុងពេលកន្លងមក។ ជំហានដំបូងនៃគម្រោងសាកល្បងនេះ នឹងអនុញ្ញាតឱ្យយើងអាចវិភាគបានម៉ត់ចត់ ស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ មុននឹងធ្វើការពង្រីកទៅកាន់វិសាលភាព ដែលបានគ្រោងទុក ដើម្បីជៀសវាងនូវហានិភ័យដែលអាចនាំឱ្យប៉ះពាល់ទៅដល់ភាពជោគជ័យនៃកម្មវិធីគោលនយោបាយទាំងមូល។ គម្រោងសាកល្បងនេះនឹងផ្ដល់ទិន្នន័យសំខាន់ៗលើសម្មតិកម្មមួយចំនួន ដើម្បីយកទៅរៀបចំកែសម្រួល មុននឹងអនុវត្តពេញលេញ។ ភាពជោគជ័យនៅក្នុងដំណាក់កាលអនុវត្តសាកល្បង ក៏នឹងផ្ដល់ជាសន្ទុះវិជ្ជមានដ៏ចាំបាច់ និងជាកត្តាអំណោយផលដល់ការពង្រីកវិសាលភាពសហគមន៍កសិកម្មទំនើប នៅកម្ពុជាក្នុងល្បឿនលឿននាពេលអនាគតផងដែរ។

## ៧.២. គោលបំណងជាក់លាក់ និងលទ្ធផលរំពឹងទុកពីគម្រោងសាកល្បង

គម្រោងសាកល្បងនៃសហគមន៍កសិកម្មទំនើប នឹងត្រូវបានរៀបចំឡើងក្នុងគោលបំណង៖

- ប្រមូលទិន្នន័យពីចរិតសេដ្ឋកិច្ច (Economic Characteristics) នៃសហគមន៍កសិកម្មទំនើប ជាពិសេស ការប្រែប្រួលនៃទំហំចំណូលចំណាយ និងប្រាក់ចំណេញរបស់កសិករជាសមាជិកម្នាក់ៗ ធៀបនឹងការធ្វើកសិកម្មតាមបែបគ្រួសារដោយមិនបានត្រឹមត្រូវតាម លក្ខណៈបច្ចេកទេស និងការស្វែងយល់ពីទំហំអប្បបរិមានៃសហគមន៍ ដើម្បីទទួលបានផលប្រយោជន៍ពីសេដ្ឋកិច្ចមាត្រដ្ឋាន (Economies of Scale)
- សាកល្បងទម្រង់សហគមន៍កសិកម្មទំនើប ដែលមានសមាហរណកម្មខ្ពស់ ធ្វើផលិតកម្មកសិកម្មរួមគ្នា (Production Cooperative) ទិញ

ធាតុចូលរួមគ្នា (Supply Chain Cooperative) និងលក់ទៅកាន់ទីផ្សាររួមគ្នា (Marketing Cooperative)

- សិក្សាពីផវភាព (Dynamics) នៃការគ្រប់គ្រងរួមគ្នា និងការទទួលខុសត្រូវជាច់ដោយឡែកពីគ្នា រវាងសមាជិកទូទៅ ក្រុមប្រឹក្សាភិបាល និងអ្នកគ្រប់គ្រងប្រតិបត្តិការរបស់សហគមន៍កសិកម្មទំនើប
- សិក្សាពីភាពទាក់ទាញ និងកត្តាលើកទឹកចិត្ត (Incentives) ដែលជំរុញឱ្យកសិករចូលរួមជាមួយសហគមន៍កសិកម្មទំនើប
- ប្រមូលយោបល់ត្រលប់ពីតម្រូវការ និងបញ្ហាប្រឈមរបស់កសិករសមាជិក ដើម្បីជាមូលដ្ឋានដល់ការវិភាគ ប្រៀបធៀប កែតម្រូវមុននឹងអនុវត្តពេញលេញ
- ស្វែងយល់ពីវិធីសាស្ត្រជំរុញភាពជាម្ចាស់ របៀបធ្វើការអភិបាលកិច្ចការអនុវត្តផែនការអាជីវកម្ម និងការសម្រេចចិត្តរបស់សហគមន៍កសិកម្មទំនើប ជាពិសេសការប្រាស្រ័យទាក់ទងគ្នារវាងសមាជិកនិងសមាជិក និងជាមួយអ្នកគ្រប់គ្រង
- ផ្សព្វផ្សាយ និងទាក់ទាញចំណាប់អារម្មណ៍ពីសំណាក់កសិករដទៃដែលនៅក្រៅសហគមន៍កសិកម្មទំនើប
- ធ្វើការវាយតម្លៃ និងលើកជាអនុសាសន៍ (Insights and Recommendation) ដើម្បីជាធាតុចូលដល់ផែនការពង្រីក និងអនុវត្តពេញលេញនៃសហគមន៍កសិកម្មទំនើបនៅក្នុងក្របខ័ណ្ឌទូទាំងប្រទេស
- ជារួមគោលដៅនៃគម្រោង គឺដើម្បីស្វែងរករូបមន្តដែលមានប្រសិទ្ធភាពមួយ ដើម្បីយកទៅធ្វើជាមូលដ្ឋាននៅក្នុងការពង្រីក និងយកគំរូតាម (Scalability and Replicability) នៅក្នុងដំណាក់កាលអនុវត្តពេញលេញ។

## ៧.៣. វិធីសាស្ត្រ និងវិសាលភាពនៃគម្រោងសាកល្បង

- **លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសទីតាំង និងកសិករគោលដៅ**
  - កសិករម្នាក់ៗចូលរួមដោយស្ម័គ្រចិត្ត
  - យល់ព្រមធ្វើផលិតកម្មកសិកម្មរួម និងទទួលយកការគ្រប់គ្រងរួមដោយសហគមន៍កសិកម្មទំនើប
  - មានចរិតលក្ខណៈជាតំណាង និងអាចយកទៅធ្វើជាគំរូក្នុងការអនុវត្តទ្រង់ទ្រាយធំនាពេលអនាគត
  - ស្ថិតនៅក្នុងទីតាំងដែលមានសក្តានុពលខ្ពស់ ស្របតាមគោលនយោបាយដែលមានស្រាប់ ងាយស្រួលក្នុងការពង្រីកនាពេលអនាគត និងស្ថិតនៅជិតទីផ្សារ
  - មានការចូលរួមប្រកបដោយបរិយាបន្ន និងសមធម៌ ជាពិសេស ផ្តល់ឱកាសដល់កសិករដែលមានដីផលិតកម្មតូច
  - ផ្តល់អាទិភាពដល់សហគមន៍កសិកម្មដែលមានស្រាប់ សមាជិកច្រើន ឆន្ទៈខ្ពស់ និងការដឹកនាំរឹងមាំ
  - មានការគាំទ្រពីអាជ្ញាធរមូលដ្ឋាន និងងាយស្រួលទទួលបានការសម្របសម្រួលពីមន្ត្រីជំនាញ
  - មានលទ្ធភាពអាចស្វែងរកថវិកាគាំទ្រដល់គម្រោងសាកល្បងពីប្រភពផ្សេងៗ។

- **វិសាលភាពនៃគម្រោងសាកល្បង**

ដំណាំយុទ្ធសាស្ត្រចំនួន៤ ត្រូវបានផ្តល់អាទិភាពសម្រាប់ការអភិវឌ្ឍសហគមន៍កសិកម្មទំនើបក្នុងជំហានដំបូង គឺដំណាំស្រូវ ដំណាំស្វាយចន្ទី ដំណាំ

ម្រេច និងដំណាំបន្លែ។ ទីតាំងសក្តានុពលនៅក្នុងខេត្តមួយចំនួននឹងត្រូវបានកំណត់អាទិភាព ដើម្បីយកមកអនុវត្តមុនគេក្នុងគម្រោងសាកល្បង ដូចជា ខេត្តកណ្តាល ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តកំពត ខេត្តព្រះសីហនុ ខេត្តកំពង់ធំ ខេត្តត្បូងឃ្មុំ និងខេត្តសៀមរាប។

## ៧.៤ ការវាយតម្លៃលើគម្រោងសាកល្បង

ដើម្បីធានាឱ្យបាននូវអត្ថប្រយោជន៍ជាអតិបរមាពីការអនុវត្តគម្រោងសាកល្បង ការសិក្សាវាយតម្លៃដាច់ដោយឡែកមួយទៀតនឹងត្រូវបានធ្វើឡើងក្រោយពេលគម្រោងត្រូវបានបញ្ចប់ ដោយការសិក្សានេះគួរផ្អែកលើគោលការណ៍ដូចខាងក្រោម៖

- វិភាគ និងប្រៀបធៀបលទ្ធផលទៅនឹងគោលបំណង និងមូលទិន្នន័យមុនពេលអនុវត្តគម្រោង (Baseline)
- ពិចារណាសិក្សាបែបគុណភាពនៃការសម្ភាសន៍ជាក្រុម (Focus Group Study) ដោយផ្តោតលើការពេញចិត្ត និងផលវិជ្ជមានទៅលើជីវភាពរបស់កសិករជាសមាជិកម្នាក់ៗក្រោយពេល អនុវត្តគម្រោង
- កំណត់ពីបញ្ហាប្រឈម ហានិភ័យ ការដកស្រង់បទពិសោធន៍ និងមេរៀនល្អៗ
- វិភាគលើភត្តានិរន្តរភាពរបស់សហគមន៍កសិកម្មទំនើប ដែលបានចូលរួមនៅក្នុងគម្រោងសាកល្បង
- សន្និដ្ឋាន និងផ្តល់អនុសាសន៍ ដើម្បីជាធាតុចូលដល់ការកែសម្រួល និងការរៀបចំផែនការពង្រីក និងការអនុវត្តពេញលេញនៃសហគមន៍កសិកម្មទំនើបក្នុងវិសាលភាពធំទូលាយ។

## ៨. សេចក្តីសន្និដ្ឋាន

ការកសាងសហគមន៍កសិកម្មទំនើប ជាមធ្យោបាយតែមួយគត់ ក្នុងការជំរុញប្រសិទ្ធិភាពសេដ្ឋកិច្ចនៃផលិតកម្មកសិកម្មកម្ពុជាប្រកបដោយ បរិយាបន្ន និងមានការចូលរួមពីប្រជាកសិករយ៉ាងទូលំទូលាយ។ កសិកម្មកម្ពុជាក៏នឹងអាចមានភាពប្រកួតប្រជែងខ្ពស់ជាងមុន ដោយសារការធ្វើសមាហរណកម្មនៃការប្រើប្រាស់ដី ក្នុងកម្រិតសេដ្ឋកិច្ចមាត្រដ្ឋាន ដោយមិនមានប៉ះពាល់ដល់កម្មសិទ្ធិឯកជន។

ទោះជាយ៉ាងនេះក្តី ការកសាងសហគមន៍កសិកម្មទំនើប នៅតែគោរពគោលការណ៍ចូលរួមដោយស្ម័គ្រចិត្តដោយគ្មានការបង្ខិតបង្ខំ គោរពសិទ្ធិក្នុងការចាកចេញរបស់សមាជិកតាមលក្ខន្តិកៈ ហើយនៅតែជាយន្តការបំពេញបន្ថែមដើម្បីជួយដល់ផលិតកម្មរបស់កសិករប្រកបដោយប្រសិទ្ធិភាព។

ដោយឡែក ការគាំទ្រសហគមន៍កសិកម្មទំនើបដែលរាជរដ្ឋាភិបាលបានសម្រេចបង្កើតឡើង ដូចជា ក្រុមប្រឹក្សាគោលនយោបាយ និងជាពិសេសមូលនិធិអភិវឌ្ឍសហគមន៍កសិកម្ម នឹងក្លាយជាយន្តការគាំទ្រប្រកបដោយនិរន្តរភាពហិរញ្ញវត្ថុមួយ។ សហគមន៍កសិកម្មទំនើបដ៏ជោគជ័យ នឹងបន្តចិញ្ចឹមមូលនិធិអភិវឌ្ឍសហគមន៍កសិកម្ម ដែលនឹងទ្រទ្រង់បន្តដល់ការបង្កើតសហគមន៍កសិកម្មទំនើបបន្ថែមទៀត សម្រាប់ជួយដល់ប្រជាកសិករ និងវិស័យកសិកម្មកម្ពុជា។

ជាការរំពឹងទុក កម្មវិធីគោលនយោបាយអភិវឌ្ឍសហគមន៍កសិកម្មទំនើប នឹងជួយលើកកម្ពស់កម្រិតជីវភាពប្រជាកសិករ ក៏ដូចជានឹងបង្កើនប្រសិទ្ធិភាពផលិតកម្មប្រកបដោយភាតរបរិស្ថាន និងចីរភាព៕

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១១២ សសរ**

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារចម្រុះសម្របសម្រួលខ្សែច្រវាក់តម្លៃផលិតផលកសិកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៥៦៣ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមការងារចម្រុះសម្របសម្រួលខ្សែច្រវាក់តម្លៃផលិតផលកសិកម្ម ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១- រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២- តំណាងក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣-តំណាងធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម | អនុប្រធាន |
| ៤- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥- អភិបាលរង នៃគណៈអភិបាលរាជធានី ខេត្តទទួលបន្ទុក | សមាជិក |
| ៦- អគ្គលេខាធិការ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិកអចិន្ត្រៃយ៍ |
| ៧- មន្ត្រីជំនាញក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៨- មន្ត្រីជំនាញក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៩- តំណាងវិស័យឯកជនពាក់ព័ន្ធនឹងវិស័យកសិកម្ម | សមាជិក |
| ១០- ប្រធានសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា | សមាជិក។ |

សមាសភាពជាក់ស្តែងនៃក្រុមការងារចម្រុះ ត្រូវកំណត់ដោយសេចក្តីសម្រេចដោយឡែករបស់ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ ២.-**

ក្រុមការងារចម្រុះនេះ មានភារកិច្ចដូចខាងក្រោម៖

- តាមដានការវិវឌ្ឍថ្លៃកសិផលលើទីផ្សារក្នុងនិងក្រៅប្រទេស ដើម្បីកំណត់មុខសញ្ញាកសិផលដែលអាចប្រឈមនឹងបញ្ហាបម្រែបម្រួលថ្លៃ
- វិភាគពីផលវិបាកនៃការប្រែប្រួលថ្លៃចំពោះអ្នកផលិត និងអ្នកប្រើប្រាស់ក្នុងប្រទេស
- ផ្អែកលើការវិភាគ កំណត់ថាផលិតផលកសិកម្មណាមួយដែលអាចនឹងជួបវិបត្តិ និងត្រូវការអន្តរាគមន៍ពីរាជរដ្ឋាភិបាល
- រៀបចំរបាយការណ៍ស្នើសុំការសម្រេចធ្វើអន្តរាគមន៍លើកសិផលណាមួយ ដែលអាចនឹងជួបវិបត្តិ ទៅប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុវត្តវិធានការអន្តរាគមន៍តាមគោលការណ៍សម្រេចរបស់ ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រាយការណ៍អំពីវឌ្ឍនភាព និងលទ្ធផលនៃកិច្ចអន្តរាគមន៍ជូន ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមការចាំបាច់
- រៀបចំបង្កើតយន្តការនិងនីតិវិធីរួម (SOP) សម្រាប់ធ្វើអន្តរាគមន៍លើខ្សែច្រវាក់តម្លៃក្នុងករណីចាំបាច់ដោយគោរពគោលការណ៍ទីផ្សារសេរីជាចម្បង
- បំពេញភារកិច្ចផ្សេងៗទៀត តាមការណែនាំរបស់ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៣.-**

សមាជិកអចិន្ត្រៃយ៍មានតួនាទីជាលេខា នៃក្រុមការងារចម្រុះ និងមានសេនាធិការមកពីអង្គភាពជំនាញតាមការចាំបាច់។

**ប្រការ ៤.-**

អនុប្រធាន និងសមាជិក ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណី ប្រធានអវត្តមាន ប្រធានអាចផ្ទេរសិទ្ធិជូនអនុប្រធានណាមួយ ដើម្បីដឹកនាំកិច្ចប្រជុំជំនួសបាន។

ក្រុមការងារចម្រុះនេះ អាចអញ្ជើញអ្នកជំនាញ ឬតំណាងក្រសួង-ស្ថាប័ន អង្គភាព និងភាគីពាក់ព័ន្ធផ្សេងៗទៀត ចូលរួមក្នុងកិច្ចប្រជុំតាមការចាំបាច់។

ក្រុមការងារចម្រុះនេះ មានសិទ្ធិប្រើត្រារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន។

**ប្រការ ៥.-**

ថវិកាចំណាយអនុវត្តយន្តការសម្របសម្រួលខ្សែច្រវាក់តម្លៃផលិតផលកសិកម្ម ត្រូវគ្រោងនៅក្នុងកញ្ចប់ថវិកាកម្មវិធីរបស់ក្រសួង-ស្ថាប័ននីមួយៗ។

**ប្រការ ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ៦ កើត ខែ ភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០៥៦......សហវ.ភ.ស.រ.គ.ស.ម

# សេចក្ដីសម្រេច
## ស្ដីពី
## ការតែងតាំងសមាសភាពក្រុមការងារចម្រុះ សម្របសម្រួលខ្សែច្រវាក់តម្លៃផលិតផលកសិកម្ម

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/២០៦៨ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំង និងផ្ដល់ឋានៈជាទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៥៦៣ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣ ស្ដីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ របស់រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញសេចក្ដីសម្រេចលេខ១១២ សសរ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្ដីពីការបង្កើតក្រុមការងារចម្រុះសម្របសម្រួលខ្សែច្រវាក់តម្លៃផលិតផលកសិកម្ម
- យោងតាមតម្រូវការចាំបាច់របស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
Phone: (855) 23 890 666
mef.cabinet@mef.gov.kh

## **សម្រេច**

**ប្រការ១ ._**

ត្រូវបានតែងតាំងសមាសភាពក្រុមការងារចម្រុះសម្របសម្រួលខ្សែច្រវាក់តម្លៃផលិតផលកសិកម្ម ដែលមានសមាសភាពដូចខាងក្រោម៖

១- ឯកឧត្តម **យ៉ង សាំងកុមារ** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធាន
២- ឯកឧត្តម **វ៉ា ត្រសាន** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម អនុប្រធាន
៣- ឯកឧត្តម **បាន លឹម** អគ្គនាយករងនៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម អនុប្រធាន
៤- ឯកឧត្តម **អ៊ឹង លុយណា** អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
៥- អភិបាលរងនៃគណៈអភិបាលរាជធានី ខេត្តទទួលបន្ទុក សមាជិក
៦- ឯកឧត្តម **ស្រី វុឌ្ឍី** អគ្គលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិកអចិន្ត្រៃយ៍
៧- ឯកឧត្តម **ស៊ីវិទ្ធ សាគុរា** អគ្គនាយកពាណិជ្ជកម្មក្នុងប្រទេសនៃក្រសួងពាណិជ្ជកម្ម សមាជិក
៨- លោក **ម៉ៅ ម៉េងទី** មន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
៩- តំណាងវិស័យឯកជនពាក់ព័ន្ធនឹងវិស័យកសិកម្ម សមាជិក
១០-ប្រធានសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា សមាជិក។

**ប្រការ២ ._**

ក្រុមការងារចម្រុះនេះ មានភារកិច្ចដូចតទៅ៖

- តាមដានការវិវឌ្ឍថ្លៃកសិផលលើទីផ្សារក្នុងនិងក្រៅប្រទេស ដើម្បីកំណត់មុខសញ្ញាកសិកម្មដែលអាចប្រឈមនឹងបញ្ហាបម្រែបម្រួលថ្លៃ
- វិភាគពីផលវិបាកនៃការប្រែប្រួលថ្លៃចំពោះអ្នកផលិត និងអ្នកប្រើប្រាស់ក្នុងប្រទេស
- ផ្អែកលើការវិភាគ កំណត់ថាផលិតផលកសិកម្មណាមួយដែលអាចនឹងជួបវិបត្តិ និងត្រូវការអន្តរាគមន៍ពីរាជរដ្ឋាភិបាល
- រៀបចំរបាយការណ៍ស្នើសុំការសម្រេចធ្វើអន្តរាគមន៍លើកសិផលណាមួយ ដែលអាចនឹងជួបវិបត្តិ ទៅប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុវត្តវិធានការអន្តរាគមន៍តាមគោលការណ៍សម្រេច របស់ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រាយការណ៍វាំពីវឌ្ឍនភាព និងលទ្ធផលនៃកិច្ចអន្តរាគមន៍ ជូនប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមការចាំបាច់
- រៀបចំបង្កើតយន្តការនិងនីតិវិធីរួម (SOP) សម្រាប់ធ្វើអន្តរាគមន៍លើខ្សែច្រវាក់តម្លៃក្នុងករណីចាំបាច់ដោយគោរពគោលការណ៍ទីផ្សារសេរីជាចម្បង
- បំពេញភារកិច្ចផ្សេងៗទៀតតាមការណែនាំ របស់ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៣ ._**

សមាជិកអចិន្ត្រៃយ៍មានតួនាទីជាលេខានៃក្រុមការងារចម្រុះ និងមានលេខាធិការរងពីរអង្គភាពជំនាញតាមការចាំបាច់។

**ប្រការ៤._**

អនុប្រធាន និងសមាជិក ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណី ប្រធានអវត្តមាន ប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធានណាមួយ ដើម្បីដឹកនាំប្រជុំជំនួសបាន។

ក្រុមការងារចម្រុះនេះ អាចអញ្ជើញអ្នកជំនាញ ឬតំណាងក្រសួង-ស្ថាប័ន អង្គភាព និងភាគីពាក់ព័ន្ធផ្សេងៗទៀត ចូលរួមក្នុងកិច្ចប្រជុំតាមការចាំបាច់។

ក្រុមការងារចម្រុះនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន។

**ប្រការ៥._**

ថវិកាអនុវត្តយន្តការសម្របសម្រួលខ្សែច្រវាក់តម្លៃផលិតផលកសិកម្ម ត្រូវគ្រោងនៅក្នុងកញ្ចប់ថវិកាកម្មវិធីរបស់ក្រសួង-ស្ថាប័ននីមួយៗ។

**ប្រការ៦._**

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃ ៧ ១០ កើត ខែ [illegible] ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- ឯកសារ កាលប្បវត្តិ

# តារាងផែនការសកម្មភាពស្តីពីការជ្រើសរើស និងការគ្រប់គ្រងមន្ត្រីកសិកម្មឃុំ-សង្កាត់

| ផែនការសកម្មភាព | សូចនាករសមិទ្ធកម្ម | ឆ្នាំអនុវត្ត | | | | ស្ថាប័នទទួលបន្ទុក |
|---|---|---|---|---|---|---|
| | | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | |
| **ការជ្រើសរើស** | | | | | | |
| ការជ្រើសរើសដំណាក់កាលទី១ | ជ្រើសរើសចំនួន ២៥០ នាក់ | √ | | | | -ក្រសួងមុខងារសាធារណៈ<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ការជ្រើសរើសដំណាក់កាលទី២ | ជ្រើសរើសចំនួន ៨០០ នាក់ | | √ | | | -ក្រសួងមុខងារសាធារណៈ<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

| | | | | | | |
|---|---|---|---|---|---|---|
| ការជ្រើសរើសដំណាក់កាលទី៣ | ជ្រើសរើសចំនួន ៥៥០ នាក់ | | | √ | | -ក្រសួងមុខងារសាធារណៈ<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ២. ការគ្រប់គ្រង | | | | | | |
| ការរៀបចំលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ | រៀបចំព្រះរាជក្រឹត្យស្ដីពីលក្ខន្តិកៈដោយឡែកនៃមន្ត្រីកសិកម្មឃុំ-សង្កាត់ | √ | | | | - ទីស្ដីការគណៈរដ្ឋមន្ត្រី<br>- ក្រសួងមុខងារសាធារណៈ<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| | រៀបចំសេចក្ដីសម្រេចស្ដីពីការបង្កើតលេខាធិការដ្ឋានសម្របសម្រួលការអនុវត្ត | | √ | | | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

| | | | | | | |
|---|---|---|---|---|---|---|
| | ការងាររបស់មន្រ្តីកសិកម្មឃុំ-សង្កាត់ | | | | | |
| | ប្រកាសស្តីពីគោលការណ៍នីតិវិធីនៃការអនុវត្តការងាររបស់មន្រ្តីកសិកម្មឃុំ-សង្កាត់ | | √ | | | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៣. ការងារបណ្តុះបណ្តាល | | | | | | |
| ការបណ្តុះបណ្តាលដំបូង | បណ្តុះបណ្តាលចំនួន ២៥០ នាក់ | | √ | | | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| | បណ្តុះបណ្តាលចំនួន ៨០០ នាក់ | | √ | | | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| | បណ្តុះបណ្តាលចំនួន ៥៥០ នាក់ | | | √ | | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

| | | | | | | |
|---|---|---|---|---|---|---|
| ការកសិក្សានិងវាយតម្លៃបណ្តុះបណ្តាលបច្ចេកទេស និងជំនាញពាក់ព័ន្ធ | រៀបចំរបាយការណ៍ស្តីពីសិក្សា និងវាយតម្លៃតម្រូវបណ្តុះបណ្តាលបច្ចេកទេស និង ជំនាញពាក់ព័ន្ធ | | √ | | | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ការបណ្តុះបណ្តាលបច្ចេកទេស | រៀបចំវគ្គបណ្តុះបណ្តាលបច្ចេកទេស | | √ | √ | √ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៤. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ | | | | | | |
| ការចុះតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការងារមន្ត្រីកសិកម្មឃុំ-សង្កាត់ | រៀបចំរបាយការណ៍ស្តីពីការចុះតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការងារ | | √ | √ | √ | -ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>-រដ្ឋបាលថ្នាក់ក្រោមជាតិ<br>-មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត |

## ៧ ជំហាន ធ្វើស្រែជោគជ័យ

(បទកាកគតិ)

ស្រូវថោកស្រូវថ្លៃ ពិតច្បាស់អាស្រ័យ លើថ្លៃជាតុចូល
មានដីពូជថ្នាំ ទីផ្សារប្រមូល ចង់បានចំណូល
ត្រូវកាត់ចំណាយ។

សូមជូនជាទាន ប្រាំពីរជំហាន ឥតមាននឿយណាយ
មួយរើសពូជល្អ សុទ្ធ ដំណើប ខ្សាយ ស្របតាមតម្រាយ
ទីផ្សារដំណាំ។

ពីរត្រូវឃ្នាតខ្មី រៀបពង្រាបដី លៃជាប្រចាំ
ដាក់ទឹកឆាប់ពេញ ចំណេញពលកម្ម បង្កើនភាពស៊ាំ
ដាំល្អអស្ចារ្យ។

បីដាំជាជួរ ដុះល្អសមគួរ ស្រូវមានសក្កា
ឈ្មោះស្មៅ ជំងឺ សត្វចយប្រហារ ផលច្រើនក្រៃណា
ថយពូជថ្នាំទៀត។

បួនត្រូវប្រើជី ធម្មជាតិគីមី ចម្រុះសារជាតុ
តាមអាយុកាល ស្រូវល្អព្រោងព្រាត ដើមមាំធំមាឌ
ក្រួរវែងត្រស៊ុំ។

ប្រាំចូរចាំថា រៀបកិច្ចសន្យា ចងគ្នាជាក្រុម
ងាយស្រួលចរចា ជាសហគមន៍ សាមគ្គីសុខុម
ដោយក្តីស្មោះសរ។

ប្រាំមួយត្រូវច្រូត មិនយឺត មិនស្រួត ច្បូតស្រូវទុំល្អ
ច្រូតខ្ចី ស្រូវថោក ទុំពេក ជ្រុះស្រ សម្អាតឧបករណ៍
ខ្លាចពូជលាយជ្រំ។

ប្រាំពីរសូមផ្តាំ តាមដានប្រចាំ ឧតុនិយម
ជំនន់ រាំងស្ងួត លែងព្រួយសន្ធំ គ្រោះភ្លាយលាភធំ
សុខុមរៀងអើយ។

